ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភ៌យ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា សួរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ព្រះរាជក្រិត្យ ក្រមទសភរិយា (តមក) | ៦៤១ |
| លោក ផេង-ដេរ សាស្ត្រាចារ្យ | បក្សីទិព្វ រឿងព្រេងប្រទេសរូម៉ានី (ត-ចប់) | ៦៤៨ |
| លោក ម៉ុញ - តាំត្រី | ស័ព្ទបារាំងប្រែជាខ្មែរ (តមក) | ៦៥៣ |
| លោកសាង - សាភ៌ត លេខានុការ | រឿងព្រេងភូមា (តមក) | ៦៦១ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក) | ៦៦៣ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | ៦៧៧ |
| អ្នកអង្គម្ចាស់ក្សត្រី ឧ. សុខានារី | សារាចារវត្តអដ្ឋារស | ៦៨៥ |
| លោកផេង-ដេរ | ប្រវត្តិរបស់អេសុប | ៦៩០ |

| ផ្នែកសាសនា | | |
|---|---|---|
| អ្នកឧកញ៉ាទេពពិទូរ ឈឹមក្រសេម | ប្រវត្តិព្រះកែវមរកត | ៦៩៦ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ប្រវត្តិព្រះអនុរុទ្ធត្ថេរ | ៧០២ |
| សាមណេរ គក- គីឡេង | រឿងនាងបដាចារ | ៧០៣ |
| លោក អ៊ុម - គយ សាស្ត្រាចារ្យ | ប្រវត្តិព្រាហ្មណ៍ចាស់ | ៧១២ |

| កំណត់ទីនប្រវត្តិការណ៍ | | |
|---|---|---|
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) | ៧១៩ |


ឆ្នាំទី ២២ – លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៥០ – ដំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។
1 9 ៧ 1950

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc
Kramakar à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable
Brah Déba Sattha So-Hay membre de la Commission du Tripitaka

## *TABLE DES MATIÈRES*

**Partie littéraire** :


| | | page |
|---|---|---|
| Luong Nibandhamantri Nhok-Thèm | Edit royal : Kramadasabhariyâ (suite) | 641 |
| M. Pheng-Chrieu, Professeur au Collège des jeunes filles | l'Oiseau du Paradis (Conte roumain) (suite et fin) | 648 |
| M. Menh-Nakry | Recueil des mots traduits par la commission Culturelle (suite) | 657 |
| M. Sang-Savath, Secrétaire au Ministère des Finances | Contes birmans (suite) | 661 |
| Neak Oknha Vibularajaséna Nou-Kàn | Histoire de SAMKOK (suite) | 667 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite) | 677 |
| Contesse Norodom Sukhanari, secrétaire de la Commission des Mœurs et Coutumes | Notice historique de Vat Attharasa | 685 |
| M. Pheng Chrieu, professeur au Collège des Jeunes Filles | Biographie d'Esope | 690 |
| **Partie religieuse** : | | |
| Neak oknha Debabidura Chhim-Krasem | Historique du Bouddha d'émeraude | 696 |
| Luong Nibandhamantri Nhok-Them | Biographie d'Anuruddhatthera | 702 |
| Samanera Kok-Kileng | Histoire de Neang Patâcàra (poème) | 707 |
| Oum-Koy professeur à l'Ecole supérieure de Pali | Biographie du vieux Brahmana | 712 |
| **Notes et Chroniques** | | |
| Ministère des Cultes | Nomination des nouveaux Chau- | |

# ព្រះរាជក្រឹត្យ

# ក្រមទសភរិយា

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា (ចៅពញាសួរ) គ. ស. ១៦៩៣

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តចក)

---

មាត្រា ១. សោត ទោះអ្នកផងទុកស្នេហ៍ [១] កូនក្រមុំឲ្យឆ្កួតកូនគេ បន្ទួ [២] ក្តី យំស្រែកក្តី ឆ្កួតកូនក្រមុំគេក្តី នោះឲ្យពិន័យអានោះ ជាប្រាក់ តម្លឹង ៣ ឲ្យហូតខ្វាត់ព្រះឃ្លាំងពុះគ្រឹង ។ បើពុំបានឆ្កួត-បន្ទួ-យំស្រែកឡើយ ឲ្យពិន័យតម្លឹង ១៥ បាទ ២ ឲ្យហូតខ្វាត់ព្រះឃ្លាំងពុះគ្រឹង ជើងកោះខ្វាត់ដំនុំបានទៅចៅហ្វាយស្រុក ពុះគ្រឹងបានមកចៅពញា ជាខុនភ្នាក់ងារ ឯខ្វាត់ខុនភ្នាក់ងារឲ្យយកតម្លឹង ៣ ហោង ។

មាត្រា ១ សោត ទោះបើអ្នកផងទៅស្ទន់អន្ទករទើងកូនក្រមុំគេ បើពុំបានកូនក្តី បង្កើតបានកូន ១ ក្តី កូន ២ ក្តី កូន ៣ ក្តី រាលែងគ្នាវិញ ទើងចំគ្តារាឯងក្តី មានអ្នកដទៃបង្ហូនបញ្ចោះបង្គាប់ឲ្យលែងក្តី ទុកអានោះ (មេនោះ) ជារាយកអំណាចរាជសក្តិព្រះបាទអ្នកជាអម្ចាស់ឲ្យប្រាណីយកក្រយាពិន័យ តម្លឹង ១៥ ជើងកោះស្លឹង ១០ ។ បើអាពុកម្តាយឯស្រីនូវ

---

១ ទុកស្នេហ៍ - គឺដាក់ស្នេហ៍ ។ ២ បន្ទួ. គឺពោលពាក្យបើរភាយ ។

ÉCOLE FRANÇAISE (BIBLIOTHÈQUE) D'EXTRÊME ORIENT

ម្តាយអាពុកឯប្រុសនោះ ពុំស្រដីពុំប្រាប់ខុនភ្នាក់ងារ ឧកញ៉ាសុភាធិបតី នូវភ្នាក់ងារស្រុកឲ្យបានដឹងផងឡើយ ឲ្យចាប់អាចោរនោះមកធ្វើក្តី រកឃើញជាមាជាម្តាយមិនជាបងជាប្អូន ... បើមានខ្ញុំ មានក្របី មានគោរទេះនូវសារពើរបស់នោះឲ្យបែងចែកបានម្ចាស់របស់ភាគ ២ បានខុនភ្នាក់ងារភាគ ១ ឯអាចោរមេចោរនោះ ឲ្យពិន័យតាមអំណាចព្រះបាទអ្នកជាអម្ចាស់នោះហោង[១] ។

មាត្រា ១ សោត ទោះបីអ្នកឯណានាំម្រត់កូនក្រមុំគេទៅហើយ ឯម្តាយអាពុកឯស្រីនោះឃើញដឹងហើយ ពុំស្រដីពុំប្រាប់កូនក្រមុំឯងឡើយ ឲ្យកូនក្រមុំឯងមានប្តីឯទៀតវិញ ឲ្យចាប់អាពុកម្តាយនោះ ជាបំបាំងព្រះរាជទ្រព្យ ឲ្យពិន័យម្តាយអាពុកស្រីនោះ ជាប្រាក់ដឹង ៣ តម្លឹង ១៧ កុំសន្ធិះឡើយ ។ ឯអាប្រុសដែលវានាំម្រត់នោះ ឲ្យពិន័យ

---

១ តាមដំណើរសេចក្តីនៃមាត្រានេះពិតស្តាប់ពិងយល់បន្តិច ព្រោះគេបានរៀបរៀងសេចក្តីខុសទំនងឆ្ងាយនឹងរបៀបសេចក្តីសម័យនេះ ។ បើតាមមតិរបស់អ្នករួបរួមព្រះរាជក្រឹត្យនេះ មានសេចក្តីយល់ដូច្នេះៈ អ្នកណាមួយទៅសហាយស្មន់នឹងកូនក្រមុំគេ មានកូនក្តី ឥតកូនក្តី ហើយសុខចិត្តលែងគ្នាតែរៀងខ្លួនក្តី មានអ្នកជិវ ឬបងប្អូនបញ្ចេះឲ្យលែងគ្នាក្តី នោះត្រូវពិន័យចំពោះរូបស្វាមីភរិយាជាប្រាក់ ១៥ តម្លឹង ដើងកោះ ១០ ស្លឹង ។ បើអាពុកម្តាយខាងប្រុសក្តី ខាងស្រីក្តីមិនបានប្តឹងឲ្យភ្នាក់ងារបានដឹងទេ នោះត្រូវចាប់អាប្រុសមកសួរបញ្ជាក់ បើរកទៅឃើញជាមាមីងបងប្អូនបញ្ចេះមែន ត្រូវឲ្យអ្នកសយកទ្រព្យសម្បត្តិរបស់អ្នកញុះញង់បំបែកបំបាក់ប្តីប្រពន្ធគេនោះ ហើយបែងជា ៣ ភាគ គឺ ២ ភាគបានម្ចាស់ទ្រព្យ ១ ភាគបានទៅខុនភ្នាក់ងារ ។ ឯសាមីប្តីប្រពន្ធនោះឲ្យពិន័យតាមអំណាចព្រះមហាក្សត្រ ។

តម្លឹង ១៩ ដ្បិតវាជាចោរលួច នាំម្រែតកូនក្រមុំគេបង្កាច់ខ្មាសហើយបិទបាំងឲ្យទៅនៅនឹងម្តាយអាពុកវិញ ។ ក្តីម្រែតយកជាប្រពន្ធហើយ ពុំប្រាប់ពុំស្រដីដោយច្បាប់ឡើយ សឹងបានជាខ្វាត់ព្រះឃ្លាំងតម្លឹង ៦ បានខ្វាត់មកខ្លួនភ្នាក់ងារតម្លឹង ៣ ហោង ។

មាត្រា ១ សោត ទោះខ្ញុំគេនឹងខ្ញុំគេវាជាអន្ទករផងគ្នា បានកូនប៉ុន្មានៗក្តី ពុំបានកូនក្តី បើវាលែងគ្នាវិញនោះ ឲ្យខ្លួនភ្នាក់ងារយកខ្វាត់បាទ ៦ នូវជើងកោះបាទ ៥ និមួយគួ ។ បើម្ចាស់ពុំបានប្រាប់ភ្នាក់ងារស្រុក នូវខ្លួនភ្នាក់ងារនោះ ទុកជាបំបាំងព្រះរាជទ្រព្យ ឲ្យពិន័យតាមច្បាប់ហោង ។

មាត្រា ១ សោត ទោះអ្នកផងទៅស្នូនអន្ទករនឹងខ្ញុំគេមានកូន ១ ក្តី កូន ២ ក្តី កូន ៣ ក្តី បើលែងគ្នាវិញនោះ ឲ្យខ្លួនភ្នាក់ងារ ហូតយកខ្វាត់បាទ ៦ មេស្រីខ្ញុំគេបាទ ៣ ជើងកោះបាទ ៥ និមួយគួ ។ បើប្រុសជាអន្ទករនឹង ( ស្រី ) ដែលខ្ញុំលែងនោះ ពុំបានប្រាប់ភ្នាក់ងារស្រុក នូវខ្លួនភ្នាក់ងារនោះ ទុកជាបំបាំងព្រះរាជទ្រព្យ ព្រះបាទអ្នកជាម្ចាស់ហោង ។ បើមានកូនប៉ុន្មានៗ ឲ្យចែកផ្នែកមេផ្នែកបា តាមព្រះច្បាប់ហោង ។

មាត្រា ១ នរអ្នកផងឯណា ពញា, ព្រះ, ហ្លួន; ជី, ទោឯណា ផងទាំងពួង យកគ្នាជាប្តីជាប្រពន្ធហើយអារពុំមានកូនឡើយ ស្លាប់ពីក្សែរ

នោះត្រូវមុខងារទុកញ្ញាសុភាធិបតីយកទ្រព្យអាករជាជង្វាយព្រះបាទអ្នកជាអម្ចាស់ ទោះមានទ្រព្យរបស់តិចច្រើនប៉ុន្មានៗ ក្តី មានកូនធម៌ មាម្តាយមីង បងប្អូនក្មួយ ទៅក្តី នោះព្រះក្រឹត្យដីកាឲ្យយកអស់ទ្រព្យរបស់ទាំងនោះមកកាត់ថ្លៃហើយបែងជាភាគ ៥ ភាគ ៣ បានជាជង្វាយ ភាគ ២ បានអ្នករស់នៅហោង ៗ

មាត្រា ១ (សោត) ទោះកូនធម៌ចាប់កូនក្រមុំគេទាំងអំណាចទាំងថ្ងៃ (ក្តី) ឯពន់ព្រលប់ក្តី ឲ្យពិន័យអាប្រុសនោះជាប្រាក់ជីង ១ តម្លឹង ៥ ដើងកោះបាទ ៥ ល្បារឃោងបាទ ១ នោះឲ្យចៅពញាជាខុនភ្នាក់ងារហូតយកខ្វាត់ព្រះឃ្លាំងពុះក្រឹង ខ្វាត់ខុនភ្នាក់ងារតម្លឹង ៣ ហោង ៗ

មាត្រា ១ (សោត) ទោះអ្នកផងនាំការកូនក្រមុំគេក្តី ជាមេអណ្តើកប្រពន្ធគេក្តី ជាមេអណ្តើកខ្ញុំគេក្តី បើរកទៅ (ឃើញ) ប្រាកដឲ្យពិន័យមេនាំការជាប្រាក់តម្លឹង ១៥ កំបាន តម្លឹង ៦ កំបានដើងកោះស្លឹង ១០ និមួយគួ ៗ លាងខ្វាសកូនក្រមុំគេ នូវអ្នកជានូវខ្ញុំគេជាប្រាក់បាទ ៦ ហោង ៗ

មាត្រា ១ (សោត) ទោះបើអ្នកផងឲ្យទៅដណ្តឹងកូនក្រមុំគេនឹងយកជាប្រពន្ធកូនប្រុសឯង នោះបើកូនប្រុសនោះក្តី កូនស្រីនោះក្តី បើនៅពុំគង់នឹងសណ្តាប់ម្តាយអាពុកទុកដាក់ឡើយ រាប់ប្រែខ្វទៅយកប្រពន្ធឯទៀតដទៃក្តី ប្រពន្ធបើរាបេញទៅជាអន្ទករនឹងប្រុសឯទៀតក្តី នោះឲ្យ

ចៅពញាជាខុនក្លាក់ង៉ារ ហូតយកខាត់តម្លឹង ៦ បាទ ១ ដាក់ខាត់ព្រះយ៉ាំង នូវដើងកោះស៊ឹង ១០ និមួយតួ ខាត់ខុនក្លាក់ង៉ារតម្លឹង ៣ ហោង ។

មាត្រា ១ (សោត) ទោះបីចាប់កូនក្រមុំគេក្តី ម៉ែត់ទាំងអំណាច ទាំងវៃ (ក្តី) ឯពន់ព្រលប់ក្តី ឲ្យពិន័យជាប្រាក់តម្លឹង ៣០ និមួយតួ ហោង ។ បើស្រីនឹងប្រុសនោះឆ្លើយថាជាសង្សារនឹងគ្នាហើយឆ្លើយ ប្រាប់ទៅចៅក្រមថាជាសង្សារវ៉ៃមែន ។ បើម្តាយអាពុកពុំរ៉ាប់ឡើយឲ្យ ពិន័យស្រីនឹងប្រុសជាប្រាក់តម្លឹង ៣០ និមួយតួ ឲ្យប្រាណពីទឹកដោះមេស្រី តម្លឹង ៥ ហោង ឲ្យយកខាត់ព្រះយ៉ាំងពុះគ្រឹងថ្វាត់ថ្វាយហោង ។

មាត្រា ១ (សោត) ទោះបីអ្នកផងទៅសម្លាប់កូនក្រមុំគេក្តី ប្រពន្ធគេក្តី (យកទ្រព្យរបស់) នោះប្តី (ប្តីអាពុក) សម្លាប់វិញបាន ហោង ។ បើឆ្លើយមកឯកូនក្រមុំជាសង្សារនឹងគ្នា បើកូនក្រមុំនោះ ថាពុំបានជាសង្សារនឹងប្រុសនោះ បើប្រាកដនោះ ព្រះត្រាស់ដីកាថា ទុកជាចោរដែលចាប់បានមក ត្រាពាក្យដោយត្លូទៃ ហើយយកពាក្យ ចោរដើមក្តី មើលមុនហើយ ទើបឲ្យយកពាក្យចុងក្តីមើលក្រោយ ទើប ឲ្យចៅក្រមជំនុំពិចារណា បើចោរដើមក្តីឈ្នះ ទុកចោរចុងក្តីជាប្រវាយរបស់ ទ្រព្យឲ្យគេ ឲ្យពិន័យ ១ ជា ៣ ។ បើចោរចុងក្តីឈ្នះ ទុកជាចោរដើមក្តី ប្រលោមរបស់គេ ប្រលោមព្រៃហ្លួង ឲ្យពិន័យ ១ ជា ២ ហោង ។ បើសេចក្តីវង្វេងគ្នា បើមានបន្ទាល់ឲ្យដណ្តឹងបន្ទាល់ បើផុតបន្ទាល់ឲ្យ

ប្រកាន់ចាប់ឆ្នោត (បើ) ចោរដើមក្តី ឈ្នះបីដង ឲ្យពិន័យចោរចុងក្តី ១ ជា ៣ ។ បើចោរចុងក្តីបានទូតឈ្នះដងទៃ ... ស្រីដទៃហើយក៏យកអន្ទករនោះជាប្តីប្រពន្ធ ឲ្យសងទ្រព្យរបស់ដែលផឹកស៊ីនោះឯង ១ ជា ៣ ហោង ។ ឲ្យខុនភ្នាក់ងារយកខ្វាត់តម្លឹង ៣ ដើងកោះស៊ឹង ១០ និមួយតួហោង ។

មាត្រា ១ (សោត) បើអ្នកឯណាយកគ្នាជាប្តីប្រពន្ធហើយប្តីស្លាប់មុនហើយពុំបានលើកខ្មោចឡើយ ហើយទៅមានអន្ទករក្តី បើមានគេទៅដណ្តឹងយកជាប្រពន្ធហើយក្តី ឯព្រះច្បាប់ទុកជាកន្ទងខ្នប់(១) ។ បើខុនភ្នាក់ងារដឹងហើយ ឲ្យកាត់ក្រយាពិន័យជាប្រាក់ដីង ៣ ទាំងប្រុសទាំងស្រីនូវដើងកោះស៊ឹង ១០ និមួយតួ ហូតយកខ្វាត់ព្រះឃ្លាំងពុះគ្រឹងខ្វាត់ខុនភ្នាក់ងារតម្លឹង ៦ ហោង ។

មាត្រា ១ (សោត) នរអ្នកផងជាក្តីនឹងគ្នា ទោះបីជាខ្ញុំបំពេសជាជំពូក ទោះជាគេចង្ការប្រាក់ក្តី ទោះជាគេជំពាក់សារពើអ្វីៗ ក្តី បើចៅមានខ្លួនដែលថាគេជំពាក់ប្រាកដ នោះថាពុំបានខ្ចី ពុំបានចង្ការ ពុំបានជាខ្ញុំបំពេស ពុំបានជាជំពូកឡើយ ឲ្យចៅដែលថាគេជំពាក់ ទោះចុងក្តីឈ្នះចៅដើមក្តី ទូត ១ ឲ្យកាត់ថ្លៃរបស់នូវថ្លៃតួចៅដើមក្តីដែលជំពាក់ នូវចៅចុងក្តីនោះមកបែងភាគ ៣ ភាគ ២ ឲ្យបោលចេញ ឲ្យយកភាគ ១ មកពិន័យចៅដើមក្តី គឺឲ្យទ្វេគុណទៀង ។ ១ សោត ចៅចុងក្តីបានទូត

១ គឺកន្ទងសពប្តី ព្រោះខ្លួនមិនទាន់យកខ្មោចប្តីទៅកប់ ឬបូជាតាមទំនៀម ។

ឈ្នះឯកទូតហើយ ចៅដើមក្តីបានត្រីទូតក្តីបានទូតឈ្នះឯកទូត ត្រីទូត ទោទូតហើយចៅដើមក្តី យកទោទូតនូវត្រីទូត ទុកជាស្មើគ្នា ឲ្យយកទូត ទុកជាចុងក្តីឈ្នះចៅដើមក្តី ទូត ១ ឲ្យយកថ្លៃរបស់ ថ្លៃត្នូចៅដើមក្តីដែល ដំណាក់នៅគេមកពិន័យចៅដើមក្តី ១ ជា ២ ។ បើចៅដើមក្តីបានទូតឈ្នះ ឯកទូតក្តី ហើយចៅចុងក្តីបានត្រីទូតក្តី បើចៅដើមក្តីបានទូតឈ្នះឯកទូត នូវត្រីទូតហើយ ចៅចុងក្តីបានទោទូតនូវត្រីទូតនោះទុកជាស្មើគ្នា ឲ្យយក ឯកទូតចៅដើមក្តីឈ្នះចៅចុងក្តី ទូត ១ ឲ្យយកថ្លៃត្នូដែលដំណាក់នៅចៅ ចុងក្តី មក (បែង) ជាភាគ ៣ ភាគ ២ ឲ្យចោលចេញ ឲ្យយកភាគ ១ មកពិន័យចៅចុងក្តីជា ៤ ហោង[១] ។

បើចៅដើមក្តីបានទូតឈ្នះឯកទូត ចៅចុងក្តីបានទោទូតនូវត្រីទូត នោះ ឲ្យយកទោទូតឯកទូតនោះទុកជាស្មើគ្នា ឲ្យយកត្រីទូតទុកជាចៅទីទៃប្រ ពាក្យប្រទាំងគ្នា នោះចៅដែលកំណត់គេថាដំណាក់នោះមកចាប់ឆ្នោតលាង ខ្លួនទឹងចំណាំខ្មោច បើដែលកំណត់ចំណាំគេថាដំណាក់នោះ បានទូត ចាញ់ទាំង ៣ ដង នោះឲ្យចៅដំណាក់បំណុលគេរបស់ទ្រព្យគេសងគេពេញ ហោង ។ បើដែលកំណត់ចំណាំគេថាដំណាក់បានទូតឈ្នះ ៣ ដង នោះ ឲ្យបង្កាត់ទូវដើងកោះឲ្យចៅក្រមហើយរួចចេញហោង ។ (មានត)

---

១ មាត្រានោះមិនសមរាប់បញ្ចូលក្នុងក្រមទសភរិយាទេ ព្រោះនិយាយតែអំពីការ បង្ការប្រាក់ការ និងការដំណាក់សារពើរបស់ទ្រព្យផ្សេងៗ ។

# បក្សីធំៗ

# រឿងព្រេងប្រទេសរូម៉ានី

លោក ផេង-ជឿវ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ
ប្រែចាកភាសាបារាំង

(ត-ចប់)

---

ព្រះរាជាស្រែកឡើងថា: ឱ! ឯងទេ ដែលអាចរកបានបក្សីវិញ? ឯងហ្នឹងទេតើ ជាកូនពៅរបស់អញ ដែលអ្នកនគរស្មានថាជាស្លាប់បាត់បង់ទៅហើយ?

— បពិត្រព្រះវររាជបិតា គឺទូលព្រះបង្គំហ្នឹងហើយ!

ហើយឧនបុត្តទូរព្រះហស្តនៃព្រះរាជា រួចអង្វរសុំឲ្យហៅនាងក្រមុំដែលជាស្ត្រីបោសព្រះរាជលាននោះចូលមក ។

កាលណានាងនោះមកដល់នៅចំពីមុខ រាប្រាប់ថា: ហ្នឹងហើយគឺតួនាងស្រីក្រមុំដែលទូលព្រះបង្គំទើបនឹងនិយាយថ្វាយអម្បាញ់មិញ ។

ព្រះរាជាត្រាស់សួរថា: ប្រាកដមែនឬ? ចុះហេតុដូចម្ដេចក៏នាងនេះប្រែជាស្រីបោសព្រះរាជលានទៅវិញ? ។

— ការណ៍ហ្នឹងជាការៈនៃនាងជាអ្នកថ្លែងរឿងថ្វាយ ព្រោះទូលព្រះបង្គំឥតបានដឹងឡើយ ។

រួចរាប់បន្តរឿងខ្លួនរាំទៅទៀតថា: ទូលព្រះបង្គំ លុះឆក់បានទ្រុងសត្វហើយ ក៏បរសេះរបស់យក្សបំផាយរត់ ៗ ប៉ុន្តែខណៈនោះ ពួកសេះឯទៀត

នាំគ្នាស្រែកកញ្ជ្រៀវៈ ពាស្រែកខ្លាំងពេក ធ្វើឲ្យទូលព្រះបង្គំ ព្រឺក្បាលសំពោង តែទូលព្រះបង្គំឥតមានភ័ន្តភាំងស្មារតីអ្វីឡើយ ។ ឯពួកយក្សបានឮសំរែកសេះ ក៏នាំគ្នាដេញតាមៈ ពាដេញប្រកិតៗ រហូតដល់ព្រំដែនសីមា គឺជាទីដែលសំឡាញ់នៃទូលព្រះបង្គំនៅរង់ចាំ, ក្នុងពេលនោះបើគ្មានសំឡាញ់ទូលព្រះបង្គំឈប់ចាំនៅកន្លែងនោះទេ ទូលព្រះបង្គំទៀងតែធ្លាក់ក្នុងកណ្ដាប់ដៃយក្សជាមិនខាន ។ ប៉ុន្តែវេលានោះ សំឡាញ់ទូលព្រះបង្គំលាតដៃបន្លុះទៅរកយក្សហើយស្រែកយ៉ាងខ្លាំងថាៈ "ឈប់!" ហើយពួកយក្សហាក់ដូចជាស្ទន់ មិនអាចនឹងឈានជើង សូម្បីតែមួយជំហានក៏មិនបាន ។ សំឡាញ់ទូលព្រះបង្គំស្ទុះមកចាប់ឱបហើយត្រេកអររីករាយ ដោយបានឃើញសត្វបក្សីទិព្វ ។ ក្នុងវេលានោះ យក្សបានសន្យាថានឹងឲ្យព្រះចន្ទ្រនឹងព្រះអាទិត្យក្អំមាសនឹងក្អំប្រាក់ ដល់ទូលព្រះបង្គំ សូមឲ្យតែទូលព្រះបង្គំបង្វិលបក្សីទិព្វនឹងសេះឲ្យទៅពាវិញ ។ លុះតមកដឹងច្បាស់ថា ឧបាយកលរបស់ពាមិនអាចធ្វើឲ្យទូលព្រះបង្គំកម្រើកបាន ទើបពានិយាយអង្វរថាៈ យ៉ាងម្ដេចម្ដា សូមអាណិតឲ្យតែសេះទៅវិញ ។ ទូលព្រះបង្គំឆ្លើយតបទៅវិញថា "ត្រង់សេះកុំឲ្យព្រួយ" ហើយទូលព្រះបង្គំក៏បង្វិលសេះឲ្យទៅពាវិញ ។ រួចទូលព្រះបង្គំចេញមកជាមួយនឹងសំឡាញ់ព្រមទាំងបក្សីទិព្វដែលពួកយក្សសំឡឹងសំឡក់ដោយភ្នែកឆ្មៀកៗ ។

មកដល់ពាំងយក្សទីមួយ នាងនារីឈរចាំយើងនៅមាត់ទ្វារ ។ នាងមាណវីគ្រាន់តែគ្រវីពាត់ប្រាប់ៗ បីដង ប្រាសាទយក្សក៏រញ្ជួលគ្នា

នៅប៉ុនផ្លែត្រា ហើយនាងកាន់យកមកជាមួយ ។ ទូលព្រះបង្គំចក់នាង ដាក់ឲ្យទំពីខាងក្រោយខ្លួន ហើយបំផាយសេះតមកទៀត ។ លុះយក្ស ដឹងការណ៍ក្នុងកាលណា ក៏នាំគ្នាលើកកងពលដេញតាម ហាមាត់ ស្រែកសន្ធាប់ស្ទើរតែនឹងធ្វើឲ្យតក់ស្លុតស្លុះទៅណាពុំបាន ។ ប៉ុន្តែយើងមិន បាត់ស្មារតី ពេញដោយក្លាហាន ទូលព្រះបង្គំវាយសេះបំបោលជា មួយនឹងសំឡាញ់លឿនដូចជាខ្យល់ ។ ចំណែកពួកយក្សហោះដេញតាម រហ័សដូចចិត្តនឹក . . . ។ សំឡាញ់នៃទូលព្រះបង្គំដឹងខ្លួនថាយើងមើល ទៅស្លុះពីដៃយក្សមិនរួចទេ ក៏ឈប់ហើយលើកដៃចង្អុលចំពោះយក្ស ធ្វើឲ្យវាក្លាយខ្លួនទៅជាដុំថ្មទាំងអស់ ។ រួចយើងធ្វើដំណើរតមកទៀត មិនយូរប៉ុន្មាន ក៏បានមកដល់មាត់ព្រែកន្ទែងចាស់ ដែលជាទីលំនៅនៃ សត្វកញ្ជ្រោង ។ ខាងក្រោយ ដែលបានសម្រាកកាយយ៉ាងស្រួលនឹង អរគុណចំពោះព្រះជាម្ចាស់ដែលជួយបំពេញបំណងនៃយើង ទូលព្រះ បង្គំក៏សួរសំឡាញ់ អំពីរឿងនៃដុំថ្មទាំងឡាយដែលទូលព្រះបង្គំបាន សំគាល់ទុកកងពេលមុន ។

សំឡាញ់ទូលព្រះបង្គំឆ្លើយថា: រឿងនេះ បើខ្ញុំប្រាប់ដល់អ្នក។ នឹងមាន សេចក្តីស្តាយក្រោយ បើខ្ញុំមិននិយាយប្រាប់ ក៏អ្នកស្តាយក្រោយដែរ ។

- សូមសំឡាញ់និយាយប្រាប់ចុះ ។

សំឡាញ់ទូលព្រះបង្គំប្រាប់ថា: ដុំថ្មនេះគឺជាបងទាំងពីររបស់អ្នក

ដែលមានចិត្តប្រាថ្នាមិនស្តាប់នូវសេចក្តីអង្វរនៃខ្ញុំ ហើយថែមទាំងព្រលែងវ៉ៃឲ្យមកចាំខ្ញុំទៀត ធ្វើខ្ញុំឲ្យជាប់នៅក្នុងវាសនាអាក្រក់ពាក់ស្បែកក្រពើងរីងរៃតែយូរទៅទៀត ហេតុដូច្នេះ ទើបខ្ញុំធ្វើឲ្យក្លាយទៅជាបុប្ផាទាំងអស់ ។

ទូលព្រះបង្គំអង្វរថា: បំណាច់យើងស្រឡាញ់គ្នា ខ្ញុំសុំឲ្យអ្នកជប់បងរបស់ខ្ញុំឲ្យបានរស់ឡើងវិញផង ។

សំឡាញ់ទូលព្រះបង្គំឆ្លើយថា: សេចក្តីស្នេហានៃអ្នកជាវត្ថុមានដំឡៃរបស់ខ្ញុំ ណ្ហើយសូមបំណងនៃអ្នកសម្រេចចុះ ប៉ុន្តែអ្នកនឹងមានវិប្បដិសារីអំពីកិច្ចនេះជាមិនខាន ។

ប្រហែលមួយនាទី ទូលព្រះបង្គំមិនដឹងថាគាត់ធ្វើសញ្ញានឹងដៃដូចម្តេច ស្រាប់តែរូបបុប្ផាទាំងប៉ុន្មានហាក់ដូចជាព្រឹៗព្រឺតៗឡើង រូបព្រះរៀមនៃទូលព្រះបង្គំក៏ត្រឡប់មានជីវិតឡើងវិញ ឈរនៅហេងពីមុខទូលព្រះបង្គំ ។

យើងទាំងបីនាក់នាំគ្នាលាសំឡាញ់នៃទូលព្រះបង្គំ ហើយត្រឡប់មកព្រះនគរវិញ ។ ប៉ុន្តែព្រះរៀមទាំងពីរហាក់ដូចជាមិនសព្វព្រះរាជហឫទ័យនឹងជ័យជំនះរបស់ទូលព្រះបង្គំសោះ ។

ក្នុងពេលដែលដើរបានឆ្ងាយបន្តិចទៅ ព្រះរៀមទាំងពីរមានវាចាថា: ម្នាលប្អូន! យើងអស់កំឡាំងណាស់ ដ្បិតថ្ងៃក្តៅពេក ហើយនៅក្បែរនេះមានត្រពាំងទឹកមួយ បើដូច្នេះ យើងនឹងចុះផឹកទឹកសិន ។

ទូលព្រះបង្គំមានសេចក្តីទុកចិត្ត ក៏ព្រមតាមព្រះរៀមទៅ ។ លុះព្រះរៀមសោយរួចស្រេចហើយ ត្រូវវេនទូលព្រះបង្គំទទួលព្រះរាជទានម្ហូប, កំពុងតែលុតជង្គង់ឱនដើម្បីឲ្យមាត់ទៅដល់ទឹក ទូលព្រះបង្គំដឹងថាមានការឈឺចាប់យ៉ាងអស្ចារ្យមកប៉ះនឹងជើងមួយរំពេច ។ ទូលព្រះបង្គំចង់ងាកមករកហេតុនៃការឈឺចាប់នោះដែរតែក្រោកឈរពុំរួច គឺព្រះរៀមទាំងពីរបានកាប់ជើងទាំងពីររបស់ទូលព្រះបង្គំត្រង់កន្ទាក់អាចម៍ហើយនាំគ្នាធ្វើដំណើរហួសទៅ មិនអើពើនឹងពាក្យអង្វរ ហើយនឹងការថ្ងូរនៃទូលព្រះបង្គំ ។

ទូលព្រះបង្គំស្ថិតនៅបីយប់បីថ្ងៃក្បែរត្រពាំងទឹក ។ កាលណាមានសត្វសាហាវមករកបៀតបៀននូវទូលព្រះបង្គំ សេះរបស់ទូលព្រះបង្គំខាំការទូលព្រះបង្គំលើកឡើងពាំរត់ទៅទីឆ្ងាយ ហើយប្រាយនូវសត្វសាហាវណាដែលចង់ចូលមករកពាធានូវខ្ញុំម្ចាស់ ។

ថ្ងៃទីមួយកន្លងមក ទូលព្រះបង្គំបានប្រទះនឹងមនុស្សខ្វាក់ម្នាក់ដើរពឹមពើមដោយលំបាកដែរ ។

ទូលព្រះបង្គំសួរថា : នរណាដើរ? ។

គេឆ្លើយថា : ខ្ញុំជាមនុស្សវិកលវិការខ្វាក់ភ្នែកលំបាកណាស់, រួចគាត់ពាយរឿងរបស់គាត់ តាមដំណើរដែលបងរបស់គាត់បានខ្វេះភ្នែកគាត់ចោល ។ ទូលព្រះបង្គំរៀបរាប់រឿងរបស់ខ្ញុំម្ចាស់ប្រាប់ទៅគាត់វិញអំពីព្រះរៀមកាប់ជើងទូលព្រះបង្គំហើយនាំគ្នារត់ចោល ។

— គាត់និយាយថា ៖ បើដូច្នេះ ចូរយើងចងចាប់គ្នាធ្វើជាមិត្ត ខ្ញុំធ្វើជាជើង សំឡាញ់ធ្វើជាភ្នែក ខ្ញុំជាអ្នកដើរ សំឡាញ់ជាអ្នកមើល ហើយនៅព្រៃជិតខាងនេះ ខ្ញុំដឹងកន្លែងជាលំនៅនៃខ្លាដំរីមួយដែលឈាមរបស់វាអាចយកមកធ្វើជាថ្នាំសំរាប់កែជម្ងឺគ្រប់ជំពូកបាន ។

លុះចុះសម្រុងគ្នាហើយ យើងក៏ធ្វើដំណើរចេញទៅ ដើម្បីស្វែងរកខ្លាដំរី ។ ទីបំផុត យើងបានរកឃើញទីលំនៅរបស់វា ហើយទទួលពេលនោះ ខ្លាដំរីចេញទៅរកស៊ីបាត់ ។ សំឡាញ់កន្លាក់ដាក់ទូលព្រះបង្គំឲ្យពួននៅក្បែរគៀនទ្វារ ហើយប្រាប់ទូលព្រះបង្គំឲ្យកាប់ភ្លាមកាលណាវាត្រឡប់ចូលមកវិញ ។ ខ្លួនគាត់ទៅពួននៅខាងក្រោយឆ្ងាយខ្លះ ។ ខ្លាដំរីមិនយូរប៉ុន្មាន ក៏ត្រឡប់ចូលមកវិញ ហើយក្រោធក្តៅក្រហាយ ដោយធុំក្លិនមនុស្សលោក ។ អាការនៃខ្លាដំរីធ្វើឲ្យខ្ញុំម្ចាស់ខ្លាចក្រៃពេក ។ គ្រាន់តែវាមកដល់ទន្ទឹមទូលព្រះបង្គំៗ ព្រលែងមួយដាវយ៉ាងអស្ចារ្យ ខ្លួនវាដាច់ជាបីកំណាត់ ។

ទូលព្រះបង្គំយកឈាមក្តៅៗមកលាបអវយវៈ ហើយយកជើងមកផ្គុំគ្នា ជើងទាំងពីរក៏បានជាប់គ្នាឡើងវិញរលាយសាច់មួយ ហាក់ដូចជាមិនដែលមានរបួសអ្វីសោះ ។ ទូលព្រះបង្គំយកឈាមនោះទៅលាបភ្នែកឲ្យសំឡាញ់ទូលព្រះបង្គំផង រួចគាត់ត្រឡប់មានចក្ខុប្រសាទឡើងវិញ ។ លុះសំរេចកិច្ចរៀងខ្លួនហើយ ខាងក្រោយដែលអរគុណចំពោះព្រះជាម្ចាស់ យើងក៏លាគ្នាធ្វើដំណើរចេញទៅរៀងខ្លួន តាមយថាកម្ម ។

ទូលព្រះបង្គំមិនមានបំណងនឹងចូលមកកាន់ទីព្រះរាជវាំងតែម្តងទេ ក៏ក្លែងខ្លួនជាអ្នកគង្វាលចៀម ដោយគិតថា ស្រេចនៅព្រះជាម្ចាស់ចុះ ជាអ្នកសម្រេចនូវអំពើអកុសលនៃមនុស្សកំបុតទាំងឡាយ ។ ការសង្ឃឹមរបស់ទូលព្រះបង្គំក៏មិនអសារឥតការទេ ព្រោះអានុភាពនៃព្រះអង្គធំណាស់ ហើយការវិនិច្ឆ័យរបស់លោកទៀតសោតក៏ទៀងត្រង់ ។

ព្រះចៅរាជាធិរាជ មានព្រះបន្ទូលទៅកាន់នាងស្រីក្រមុំថា : ម្តងនេះត្រូវនាងនិយាយឲ្យយើងស្តាប់មើល តើយ៉ាងដូចម្តេច នាងក៏បានមកធ្វើជាទាសីសម្រាប់បោសព្រះរាជលាន? ។

នាងមាណវីក្រាបបង្គំទូលថា : លុះបានកាប់ជើងព្រះអណុជពៅរួចស្រេចហើយកាលណា ព្រះរៀមទាំងពីរ ម្នាក់នាំទូលព្រះបង្គំ ម្នាក់ទៀតកាន់បក្សីទិព្វចេញចោលព្រះកនិដ្ឋាមក ។ ចំណែកខ្ញុំម្ចាស់ចិត្តនៅតែប្រតិព័ទ្ធក្នុងព្រះរាជបុត្រពៅនៃព្រះអង្គជានិច្ច ព្រោះទូលព្រះបង្គំជាសាក្សីនៃសេចក្តីក្លាហានរបស់ព្រះអណុជ ។ បណ្តាព្រះរៀមទាំងពីរ មានព្រះរៀមមួយព្រះអង្គបង្ខំឲ្យទូលព្រះបង្គំយកលោកធ្វើជាព្រះស្វាមី ក្នុងពេលដែលលោកយាងមកដល់ព្រះរាជវាំង ។ ទូលព្រះបង្គំចេះតែរឹងទទឹងចំពោះសេចក្តីបំណងក្នុងការកំហែងចាប់ចង់នៃព្រះរៀមអង្គនោះ ហើយមិនព្រមចេញទៅទីដទៃ ស៊ូអត់ទ្រាំនៅធ្វើជាទាសីឆ្មាំសត្វក្ងាន និងជាស្រីបោសព្រះរាជលាន ព្រោះនឹកឃើញថា ព្រះជាម្ចាស់មិនដែលលះបង់

ហោលមនុស្សស្មុចរិតឡើយ ។ ឥឡូវនេះទូលព្រះបង្គំសូមអរព្រះគុណនៃព្រះជាម្ចាស់ដែលបានសំដែងឲ្យឃើញជាក់ច្បាស់ដល់ភ្នែកទូលព្រះបង្គំថា អំពើកុសលមិនដែលស្លាប់ ។

ព្រះចៅមានព្រះតម្រាស់សួរថា: តើនាងបានអ្វីជាបន្ទាល់ដើម្បីធ្វើឲ្យដឹងថា នាងគឺប្រាកដជាតួនាងនារីដែលកូនយើងបាននាំយកមកពីនគរយក្ស? ។

នាងមាណវីយកផ្លែពុទ្រាបង្ហាញ ហើយទូលថា: ផ្លែពុទ្រានេះ អាចបញ្ជាក់ឲ្យដឹងច្បាស់បានថាទូលព្រះបង្គំ គឺជាអ្នកណា! ព្រះរាជបុត្រនៃព្រះករុណាថ្លៃវិសេសមិនបានប្រាប់រឿងនេះទេ ព្រោះទូលព្រះបង្គំមិនដែលយកផ្លែនេះមកបង្ហាញឲ្យឃើញម្ដងឡើយ ។

នាងមាណវីចេញទៅកណ្ដាលកាល យកកាំបិតពាក់ខ្សែត្រកយបំផង ពីខាងលើផ្លែពុទ្រា ស្រាប់តែប្រាសាទយ៉ាងល្អអស្ចារ្យផុះឡើង ។ ប្រាសាទបែបនេះ ក្នុងព្រះរាជបុរីកាយ ឥតមានប្រាសាទឯណាយកមកប្រៀបផ្ទឹមបានឡើយ ។ ព្រះករុណាថ្លៃវិសេសក៏ទ្រង់សរសើរប្រាសាទនេះដែរ ។ ហើយព្រះរាជាគិតបំរុងនឹងធ្វើបុណ្យមួយជាទឡ្ហីក ដើម្បីសំដែងសេចក្ដីត្រេកអរ ចំពោះការវិលត្រឡប់មកដល់ព្រះនគរវិញនៃព្រះរាជបុត្រពៅ; ប៉ុន្តែព្រះរាជបុត្រអង្គនេះ ទូលស្នងថា: បពិត្រព្រះវររាជបិតា! មុននឹងអរគុណចំពោះព្រះជាម្ចាស់ ទូលព្រះបង្គំមានបំណងចង់

ឲ្យព្រះជាម្ចាស់វិនិច្ឆ័យយើងបីនាក់ ។ ព្រះរាជាក៏មិនហ៊ានយល់ទាស់ ។ គេនាំព្រះរាជបុត្រច្បងទាំងពីរមកហើយ ព្រះរៀមលុតជង្គង់សូមទោសចំពោះព្រះអណុជៗ និយាយថា បើព្រះជាម្ចាស់អត់ទោសឲ្យព្រះរៀម ទូលព្រះបង្គំក៏ព្រមអត់ទោសដែរ ។ ហេតុដូច្នេះត្រូវតែយើងធ្វើតាមបំណងនៃព្រះអង្គ ។

នៅមុខព្រះវិហារ គេដាក់ដើមឈើបីកំណាត់ ហើយលុងឲ្យមានប្រហោងកណ្ដាល ចម្ងាយប្រវែងគ្នាពីមួយទៅមួយ ព្រះរាជបុត្រមួយអង្គៗត្រូវចូលក្នុងប្រហោងឈើនោះ ហើយកាន់ដុំថ្មយ៉ាងធំមួយម្នាក់ រួចបោះទៅលើអាកាស ។ ដុំថ្មព្រះរាជបុត្រច្បងទាំងពីរដែលបោះទៅលើ ក៏ត្រឡប់ធ្លាក់មកលើក្បាលយ៉ាងខ្លាំង ខ្លាំងពេកទាល់តែទ្រង់ស្ដេចសុគតមួយរំពេច ។ ចំណែកដុំថ្មរបស់ព្រះរាជបុត្រពៅត្រឡប់ធ្លាក់មកខាងមុខ ។ ក្នុងវេលាដែលគេធ្វើកិច្ចល្បងនេះ មហាជនមកមើលច្រើនជាអនេក ។ ខាងក្រោយដែលព្រះចៅរាជាធិរាជបានអភិសេកផ្សំផ្គុំព្រះរាជបុត្រពៅជាមួយនឹងនាងមាណវីឆ្នាំព្រះរាជលាន ព្រះរាជបុត្រអង្គនេះ ក៏ទ្រង់ស្ដេចសោយរាជ្យស្នងព្រះអង្គឡើង ។

ចប់រឿងបក្សីទិព្វ ។

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## លោក ម៉ុញ - ឆាគ្រី រួបរួម

(តមក)

Réalisation = ការធ្វើឲ្យបានពិត, ប្រាកដ

Vérité = សច្ចៈ, សត្យ

Réalisme = ប្រាកដនិយម

(១៩ - ៨ - ៤៩)

Débouché = វិវរដ្ឋាន, ច្រកចំហ

Désidérata = ឥច្ឆិតា

Essentiel = សារវន្ត, (សារវន្តី)

Possibilité = ការអាចធ្វើបាន

Dilemme = ទ្វេគ្រោះ (ការកាន់យកពីរដង)

Alternative = ទ្វេបថ, ការផ្លាស់គ្នា

Anarchie = អនាធិបតេយ្យ

Volontaire = អ្នកស្ម័គ្រ, ដែលស្ម័គ្រ, ដែលប្រកបដោយចេតនា

Volonté = ឆន្ទៈ, សេចក្ដីស្ម័គ្រ

Bonne volonté = ឆន្ទៈល្អ

(២៦-៨-៤៩)

Fédération nationale des coopératives de con·ommation = ប្រជុំក្រុមសហករណ៍នៃគ្រឿងឧបភោគ បរិភោគ ។

Point faible = ចំណុចខ្សោយ

Le fond et la forme (d'un texte) = អត្ថរសនឹងទម្រង់ (នៃអត្ថបទ)

Grâce à = ដោយសារតែ . . .

A cause de = ព្រោះហេតុតែ . . . ពាស់តែ . .

(៣០-៨-៤៩)

Sagesse = គតិបណ្ឌិត

Sage = បណ្ឌិត

Ecole Normale d'Institutrices à Montpellier = សាលាគរុវិជ្ជាកុមារី នៅម៉ុងប៉ែល្យេរ៍

Centre Régional d'Education Physique de Dinard (Rennes) = ទីប្រជុំភូមិភាគនៃការសិក្សារូបនិយម នៅឌីណាទ៍ - (រែន្ស៍)

Académie Internationale de Coupe à Paris = បណ្ឌិតសភាអន្តរប្រទេសខាងការកាត់ដេរ នៅប៉ារីស ។

Syndicat = សហជីព

Milieu parlementaire = មជ្ឈដ្ឋានសភា

(២-៩-៤៩)

Orthodoxie = សម្មាមតិ (មតិ)

Impression (de voyage) = ការចាប់អារម្មណ៍ (នៃដំណើរ)

Improviser = មិនបានគិតទុកជាមុន

A l'improviste = ដោយមិនបានដឹងខ្លួនមុន

Impromptu = ដែលមិនបានគិតទុកជាមុន

Aventure = ការដើរផ្សងព្រេង

Aventurier = អ្នកដើរផ្សងព្រេង អ្នកដើរទេស

(៦-៩-៤៩)

Aristocrate = អភិជន

Aristocratie = អភិជនាធិបតេយ្យ

Noble = អភិជន

Noblesse = អភិជនភាព, ថ្នាក់អភិជន, គណៈអភិជន, អភិចរិយា

Bourgeoisie = ថ្នាក់ពួគណៈគហបតី

Spécialiste = អ្នកឯកទេស

Argument = ហេតុផល, ហេតុការណ៍

Argumentation = ការអាងហេតុផល

Raison = វិចារណញ្ញាណ, ត្រឹមត្រូវ, ទំនង

Bourgeois = ហេតុគហបតី

Commandement = កងបញ្ជាការ, អំណាចបង្គាប់បញ្ជា, ការបង្គាប់បញ្ជា

Raisonnable = សមហេតុសមផល

Raisonnement = ការពិចារណារកហេតុផល

(១៣–៩–៤៩)

Motif = ហេតុ

Prétexte = លេស, អន្តពេកាស

Pouvoir = អំណាច

Puissance = អានុភាព

Force = កម្លាំង

Energie = ថាមពល, ពលិន្ទ្រីយ៍

Prétexter = ធ្វៀតយកលេស, ធ្វៀតយកអន្តពេកាស

Puissance magique = មន្តានុភាព, ឥទ្ធានុភាព, រិទ្ធានុភាព (មាគធ)

រឿងព្រេងភូមា

## លោក សាង-សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

បុរសផ្សងព្រេងខ្វល់គំនិតពេក ឥតបានសាកសួរគេទេ ក៏ដើរចុះពីផ្ទះតែម្រ៉ងទៅប្តឹងលោកសុភានៅក្នុងភូមិ សុំឲ្យលោកជួយឲ្យបានប្រពន្ធមកខ្លួនវិញ ។ ឯអ្នកស្រីជាម្តាយក្មេកបុរសនេះព្រមទាំងជនានុជនច្រើនរូបទៀតត្រូវគេហៅទៅធ្វើជាសាក្សី ។ —ទេ! រឿងនេះគ្មាននាំឲ្យយើងងឿងឆ្ងល់រ៉ូសោះ ព្រោះកិរិយារបស់អ្នកស្លាប់បង់ជីវិតក្នុងកណ្តាលអណ្តាតភ្លើងទៅហើយតើ, បើមិនមែនដូច្នោះទេ ម្តាយប្រពន្ធអ្នកមិនមែនមកប្តឹងបញ្ជាក់ពីថ្ងៃមុនឡើយ នាងនេះគ្រាន់តែមានរូបកាយប្រហែលកិរិយារបស់អ្នកតើ ឯម្តាយក្មេករបស់អ្នកបានផ្ទៀតមើលមុខនាងនេះមកយូរថ្ងៃដើម្បីកុំឲ្យមានទុក្ខព្រួយពេកប៉ុណ្ណោះទេ ។ ប៉ុន្តែទោះបីបុរសនោះខំជជែកយ៉ាងណាក៏ដោយ លោកសុភាក៏មិនព្រមស្តាប់សោះ ។ ក្រោយមកលោកចៅហ្វាយខែត្រក៏បានកាត់សេចក្តីដូចលោកសុភានេះទៀត ។

លុះធ្វើសក្តាមដែលអស់សង្ឃឹមនេះហើយ, បុរសផ្សងព្រេងបានទៅទូលដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ព្រះករុណាម្ចាស់ជីវិតទ្រង់ខំស្តាប់ពាក្យបណ្តឹងយ៉ាងម៉ត់ចត់; ប៉ុន្តែទ្រង់មិនសូវប្រសប់ខាងផ្លូវ

ច្បាប់ ហើយដោយទ្រង់មានព្រះហឫទ័យបង្អៀតបង្អល់ជាពន់ពេក ។ ក្នុងពេលនោះ ទេវតាដែលគេក្រាស្ទួតប៉ុត្របានទូលទៅព្រះកាណ៌ព្រះអង្គថា: "សូមទ្រង់ព្រះមេត្តាប្រោស ! រឿងនេះធំណាស់ ហើយពិបាកផង; ជនណាដែលល្ងង់ខ្លៅជននោះមិនត្រូវមកប្រឡូកក្នុងរឿងនេះទេ; ឯលោកនាយកអភិជនរបស់ព្រះអង្គជាចៅក្រមមួយយ៉ាងប៉ិនប្រសប់, លោកនេះអាចនឹងរកការណ៍ពិតឃើញបាន" ។

ព្រះរាជាក៏ទ្រង់មានព្រះបន្ទូលហៅលោកដ៏ចំណាប់នេះ មកជិតព្រះអង្គ ហើយទ្រង់បង្គាប់ឲ្យរូបនេះបំភ្លឺរឿងនុះឡើង ។

មិនមែនជាការស្រួលទេ ដែលគេប្រគល់រឿងនេះឲ្យលោករដ្ឋមន្ត្រីដ៏វិសេសនេះ, លោកជាអ្នកប្រាជ្ញមែនពិត ប៉ុន្តែលោកមិនដឹងធ្វើយ៉ាងណាឬគិតយ៉ាងណាសោះ ។ ឯបុត្រីរបស់លោកឈ្មោះនាងធូដាម៉ាសារីម៉ង់សាមី (Thoudamna sari menzamie; បានសង្កេតឃើញកង្វល់របស់លោកដោយឥតយូរឡើយ ហើយសួរកេហេតុនេះភ្លាម ។ ឪពុកដែលទុកចិត្តតែលើរូបកូនស្រី ១ នេះ គ្រាន់តែនិយាយត្រង់ការទង្វើពិបាក ដែលព្រះករុណាទ្រង់ត្រាស់បង្គាប់ឲ្យលោកសម្រេច ។ នាងឆ្លើយថា: "សូមលោកឪពុកកុំព្រួយឲ្យសោះខ្ញុំធានាទាំងអស់ ខ្ញុំគ្រាន់តែសូមលោកឪពុកឲ្យសង់ខ្ទមមួយវែងក្នុងសួនច្បាររបស់យើង ហើយឲ្យជនទាំងអស់ដែលមានរឿងមករកខ្ញុំ, ជនម្នាក់ៗ ឈរនៅជ្រុងមួយៗ, ឯខ្ញុំនៅកណ្ដាល

ជាមួយនឹងស្មៀនរបស់ខ្ញុំម្នាក់, រួចខ្ញុំសាកសួរជនទាំងនោះម្នាក់ម្ដងៗ, ខ្ញុំហ៊ានសន្យាថាខ្ញុំរកសេចក្ដីពិតឲ្យឃើញពុំខាន" ។

លុះកាលណាធ្វើបានសព្វគ្រប់ដូចបំណងនាងហើយ នាងហៅប្ដីដើមមកហើយពោលពាក្យដូចមានតទៅនេះ "ឱអ្នកដ៏ថ្លៃថ្លា! គេនិយាយអ្នកអភ័ព្វប្រពន្ធស្លាប់ក្នុងអគ្គិភ័យ ដែលឆេះផ្ទះរបស់អ្នក កាលដែលអ្នកចេញផុតទៅធ្វើដំណើរតាមសមុទ្រ ដោយក្លាហានដើម្បីទៅរកធនធាន, ឥឡូវនេះ អ្នកបានត្រឡប់មកវិញពេញចិត្តដោយការរកធនធាននោះបានដូចបំណងរបស់អ្នក, ឯឪពុកម្ដាយរបស់អ្នកទៀតក៏ស្ងួតតែអ្នកមានទ្រព្យសម្បត្តិសម្បើមណាស់ដែរ; ចំណែកខាងមតិពិតត្រង់របស់ខ្ញុំយល់ថា មនុស្សឈ្លាសវាងវៃនឹងចុំច្រើនដូចអ្នកនេះ មិនសមឡើយមកប្ដឹងផ្ដល់ដណ្ដើមប្រពន្ធដូច្នេះទេ, ឯរូបស្រីបានប្រកាសថា គេជាប្រពន្ធពិតរបស់គូស្រករបស់អ្នក, ឯគូស្រករនេះ គេក៏ប្រកាសដូច្នេះដែរ; មួយទៀតតាំងពីស្ដេចផែនដីរហូតដល់កំទេចស្រុកក្នុងប្រទេស គេថាអ្នកខុសទាំងអស់, ឥឡូវនេះ សូមអ្នកនិយាយប្រាប់ខ្ញុំឲ្យពិតត្រង់មើល តើនាងនោះប្រាកដជាប្រពន្ធរបស់អ្នកមែនឬទេ? ហើយតើហេតុយ៉ាងណាបានជាគេស្អប់អ្នក? គួរណាស់តែអ្នកធ្វើតាមពាក្យខ្ញុំដែលដកបអ្នកដូចមានតទៅនេះ: ប៉ុន្តែខ្ញុំមិនដឹងជាអ្នកសុខចិត្តធ្វើតាមខ្ញុំឬយ៉ាងណាទេ ឯចំណែកខាងខ្ញុំៗ សឹងតែមិនហ៊ានហាមាត់និយាយផង" ។ លុះនិយាយដូច្នេះហើយ នាងអៀនខ្មាសយកដៃបិទមុខដ៏ល្អឆើតឆាយរបស់នាង ។ ក្នុងពេលនោះ

បុរសអង្វរឲ្យនាងនិយាយតទៅទៀត ។ នាងងើបមុខឡើងដាច់ចិត្តមិនខ្មាសអៀន ហើយនិយាយថា: "ឯដំបូន្មានរបស់ខ្ញុំមានដូចតទៅនេះ: រូបអ្នកជាអ្នកមានទ្រព្យសម្បត្តិ រូបខ្ញុំជាកូនរបស់លោកនាយករដ្ឋមន្ត្រីនៃព្រះមហាក្សត្រ; បើសិនណាយើងស្រឡាញ់គ្នា ហើយព្រមព្រៀងរៀបការនឹងគ្នា យើងមុខជាគ្មានទុក្ខភ័យអ្វីទេលុះអស់ជីវិតរៀងខ្លួន, អ្នកមានបុក្យពាគួរឲ្យខ្ញុំសរសើរណាស់ តើអ្នកយល់ព្រមតាមខ្ញុំទេ? ហើយចូរអ្នកឆ្លើយឲ្យត្រង់ដូចចិត្តខ្ញុំដែលបានបង្ហាញអ្នកអម្បាញ់មិញនេះ" ។ បុរសឆ្លើយបែបព្រួយបន្តិចថា: "ឯពាក្យឆ្លើយរបស់ខ្ញុំងាយទេ, ឱនាង! ខ្ញុំចាប់ចិត្តចាប់គំនិតនឹងពាក្យរបស់អ្នកនាងជាពន់ពេក, ប៉ុន្តែតើឲ្យខ្ញុំលះបង់ចោលភរិយា ដែលឪពុកម្តាយរបស់ខ្ញុំបានដាក់ទុកឲ្យម្តេចបាន? ខ្ញុំបានសន្មតក្នុងចិត្តថា នាងនេះជាគូជីវិតរបស់ខ្ញុំ ពីព្រោះយើងស្គាល់គ្នាតាំងពីតូចមក, នាងស្រាតរត់លេងយ៉ាងសប្បាយក្នុងផ្ទះរបស់យើង, មនុស្សប្រុសមិនត្រូវដាច់ចិត្តធ្វើអំពើកំណាចបំបាត់កិច្ចព្រមព្រៀង ដែលបានធ្វើយ៉ាងឱឡារិកដូច្នោះទេ" ។ នាងលុះកាលណាបានឮសំដីប្រពៃនេះហើយ នាងញញឹមទៅរកបុរសរួចបើកទ្វារឲ្យចេញទៅ, នាងបានគិតឃើញរួចជាស្រេច ។

ក្រោយមក នាងបានហៅប៉ាយតាទៅឯបន្ទប់នាង, នាងនឹកថាប៉ាយតានេះជាមនុស្សអាក្រក់ ប៉ុន្តែនាងទំលាក់ពុត ហើយសួរដោយខ្លីខ្លា

បន្តិចថា: "បុរសក្មេងៗ ទាំងពីរនាក់នេះឈ្លោះគ្នាព្រោះស្ត្រីម្នាក់យ៉ាងនេះមិនត្រូវទេ, ឯខ្ញុំជាស្រីគ្មានប្ដី បើអ្នកសុខចិត្ត ខ្ញុំព្រមយកអ្នក, ខ្ញុំជាកូនរបស់លោកនាយករដ្ឋមន្ត្រីមានទ្រព្យសម្បត្តិសម្បើមណាស់, ខ្ញុំមានមាសពេជ្រក្នុងលោកនេះគ្មានអ្នកណាស្មើ, បើយើងបានគ្នាមុខជាសប្បាយដោយទ្រព្យនិងយសស័ក្តិរបស់យើងមិនខាន" ។

ប៉ាយគា ឥតបានសង្កេតថា នាងនិយាយអំពីតណ្ហាសោះ ឃើញថានាងនិយាយតែអំពីទ្រព្យ ហើយក៏ឆ្លើយភ្លាមថាសុខចិត្ត ។ នាងទំលាក់ពុតរបស់នាង ហើយឆ្លើយថា: "បើអ្នកយល់តាមគ្រោងការនេះ យើងត្រូវនាំគ្នារត់ទៅនៅឯទីណាមួយឆ្ងាយពីទីនេះ, លុះតែធ្វើយ៉ាងនេះទើបខ្ញុំជឿថាអ្នកស្ម័គ្រស្មោះនឹងខ្ញុំ" ។ ប៉ាយគាឥតប្រកែកអ្វីមួយម៉ាត់សោះ ធ្វើមុខស្មើដូចធម្មតា ។ ឯនាងក្ដៅក្រហាយលើកដៃគ្រវាសចង្អុលទ្វារឲ្យប៉ាយគាចេញទៅ ។ ប៉ាយគានៅតែគ្មានចាប់ភ្លឹកនឹងអាការរបស់នាង ហើយថយខ្លួនយ៉ាងស្រួលបួលទៅ ក្អែករំពៃមើលនាងទៀត ។ ឯនាងគ្មានមើលវិញទេ ។

ក្រោយមកទៀត នាងហៅនាងករិយាមក ហើយនិយាយថា "អ្នកបង! ប្ដីរបស់អ្នកបងសព្វថ្ងៃក្រខ្សត់ខ្សោយ, គាត់គ្មានអ្វីសោះ ហើយគាត់មានគំនិតហាក់ដូចជាអន់ថយជាងបុរសកូនអ្នកមានជាពន់ពេក, ឯរូបគេនេះពេញលេញប្រសើរណាស់, គេមានទ្រព្យសម្បត្តិក៏ច្រើន

គេអាចនាំអ្នកបងឲ្យបានសប្បាយ, បើអ្នកបងរួមរសនឹងគេ អ្នកបងមុខជាលែងស្គាល់សេចក្តីក្រលំបាកទៀតហើយ រៀងរហូតដល់ស្លាប់ទៅវិញ, ខ្ញុំសូមឲ្យអ្នកបងប្រាប់ខ្ញុំ តើហេតុដូចម្តេចបានជាអ្នកបងមិនព្រមយកគេ? ។

នាងករិយាឆ្លើយថា "ជំរាបប្រសាសន៍អ្នកនាង! អ្នកនាងក៏ស្រី ខ្ញុំក៏ជាស្រីដែរ អាស្រ័យហេតុនេះ អ្នកនាងមុខជាយល់តាមខ្ញុំមិនខាន, មនុស្សស្រីគឺជាផ្លែឈើមួយដែលជាប់នឹងមែក, ឯប្តីទុកដូចជាដើមឈើដែលទ្រមែកនោះ, អ្នកនាងជ្រាបស្រាប់ហើយ តើធម្មជាតិធ្វើយ៉ាងណា ៗ ខ្លះ គឺដំបូងនៅលើដើមឈើមានតែត្រួយមួយទេ, ត្រួយនេះបង្កើតជាសន្ទឹកមួយប្តីប៉ុណ្ណោះ. សន្ទឹកនេះក្លាយបានទៅជាមែក, នៅលើមែកនោះផ្លាស់រូបបានទៅជាផ្កា, ឯផ្កាបានជាផ្លែ, រួចផ្លែនេះទុំជ្រុះពីលើដើមឈើ, ជួនកាលគេបេះផ្លែនេះយកទៅបរិភោគ ជួនកាលទៀតផ្លែនេះនៅរលួយលើធរណី, ហេតុដូច្នោះ ខ្ញុំសូមសួរអ្នកនាង តើផ្លែដែលជ្រុះពីលើដើមឈើ អាចភ្ជាប់ទៅកន្លែងដែលជ្រុះនោះវិញបានឬទេ? ឯកូនដែលកើតចេញពីផ្ទៃមាតាមក អាចចូលនៅកន្លែងផ្ទៃនោះវិញបានឬទេ?" ។

នេះហើយជាការៈរបស់ស្រីដែលជ្រុលខ្លួនខុស ៗ ឯការក្បត់ចិត្តរបស់ស្រីនេះ នាំឲ្យក្តួចសេចក្តីស្នេហា នឹងសេចក្តីគោរពចំពោះរូបស្វាមី ។ ហេតុដូច្នេះ បើគ្មានរបស់អ្វីមួយប្លែកអស្ចារ្យទេ ស្រីនេះគ្មានសង្ឃឹមឡើយ ទោះបីស្តីបន្ទោសខ្លួនឯងយ៉ាងណាក៏ដោយ ។

(មានត)

រឿងសាមកុក

កណ្ឌទី ៦

# អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ឡៅពៀវឆ្លើយថា សពស៊ុនកៀនដែលពួកទាហាននាំមកឲ្យយើងនោះ យើងបានតុបតែងទុកតាមប្រវេណីដោយសមគួរ, ដែលស៊ុនសឺកឲ្យអ្នកមកនិយាយនេះយើងមិនថាអ្វីទេ តែថាតទៅមុខ កុំឲ្យស៊ុនសឺកគិតបំពានចូលមកធ្វើអន្តរាយដល់យើងទៀត ។

គេងលៀងឆ្លើយជំពបឡៅពៀវថា ដែលលោកនឹងព្រមឲ្យសពស៊ុនកៀនទៅគេនោះ ខ្ញុំមិនទាន់យល់ព្រមជាមួយផងទេ ព្រោះស៊ុនកៀនបំពានមកធ្វើការទាំងនេះដោយចិត្តអាក្រក់ណាស់ ទើបដល់នូវសេចក្តីវិនាសជីវិតយ៉ាងនេះ ឯស៊ុនសឺកជាកូននៅក្មេងណាស់, សេនាទាហាន

ស៊ិនសឹកមានសេចក្ដីកោតញញើតយើងជាច្រើន បើលោកស្លាប់ខ្ញុំនឹងគិតធ្វើទាហានស្រុកកាំងតាំងដែលសល់នៅនោះ កុំឲ្យវិលទៅរួចដល់ម្នាក់ឡើយ សូមឲ្យលោកចាប់ហួនកាយនេះសម្លាប់ចេញទៅ រួចសឹមលើកទ័ពទៅកយកធរ៍ពតាំងនោះជាក្រោយ ស្រុកកាំងតាំងនោះគង់នឹងធ្លាក់មកជាកម្មសិទ្ធិរបស់លោក បើលោកមិនស្លាប់ខ្ញុំ ហើយប្រគល់សពស៊ិនកៀនទៅឲ្យគេ ប្រែក្រោយលោកគង់មានសេចក្ដីអន្តរាយជាប្រាកដ ។

ឡេវពៀវតបថា "ហាងចនឹងយើងជាមនុស្សស្រឡាញ់រាប់អានទុកចិត្តគ្នាមកពីដើម កាលបើយើងធ្វើដូច្នោះហាក់ដូចជាក្លែងសម្លាប់ហាងចឲ្យស្លាប់ សេចក្ដីដែលយើងប្រេជ្ញាទុកពីដើមក៏ខូចសាសាទៅវិញ"។ រួចហើយប្រាប់ហួនកាយឲ្យស្រុកត្រឡប់ទៅវិញ ហើយថា "ព្រឹកស្អែកឲ្យនាំខ្លួនហាងចមកប្រគល់ឲ្យយើងត្រឹមទ្វារស្រុក យើងនឹងជូនសពស៊ិនកៀនទៅឲ្យ" ។ ហួនកាយក៏នាំសេចក្ដីនោះត្រឡប់ទៅជំរាបស៊ិនសឹក។ មានសេចក្ដីត្រេកអរជាទីបំផុត, ដល់វេលាព្រឹកឡើង បានចាត់ទាហានឲ្យនាំខ្លួនហាងចទៅជូនឡេវពៀវដល់ទ្វារស្រុក ហើយទទួលយកសពស៊ិនកៀនដាក់ទូក លើកទាហានត្រឡប់ទៅស្រុកកាំងតាំងវិញ ។

កាលនាំសពឡើងទៅដល់លើទីគ្រឹហាស្ថានហើយ ក៏ឲ្យតាក់តែងគ្រឿងដង្ហែដ៏រុងរឿង នាំទៅបញ្ចុះនៅដំបន់ខយ៉ុកគុ ។ សម័យនោះស៊ិនសឹកបានឡើងយសសក្ដិជាធំក្នុងស្រុកកាំងតាំង, បណ្ដាអ្នកស្រុក

ទាំងអស់នៅក្រោមបង្គាប់បញ្ជាស៊ុនសឺក. ឯភរិយាស៊ុនសឺកនោះជាមនុស្សមានសតិបញ្ញា បើឃើញអ្នកឯណាដែលធ្វើសង្វាតខ្លាំងពូកែតែងមានសេចក្ដីគោរពកោតក្រែង ហើយចងចិត្តយកមកជាបក្សពួកធ្វើការជាមួយ មនុស្សក៏ចុះចូលកុះករមកជាច្រើន ។

## កណ្ឌទី ៣

**ចាប់តាំងពីតាំងគុះកំរើបចិត្តតាំងខ្លួនជា សងអ៊ូ (ធម្មបិតា) រូបតិតកលឧបាយនឹងសម្លាប់តៀវអ៊ុន, តមកអងអ៊ុនលួងលោមនាងតៀវសៀនជាកូនចិញ្ចឹម ឲ្យទៅធ្វើជាភរិយាលីប៉ោនឹងតាំងគុះ ដើម្បីឲ្យអ្នកទាំង ២ នេះទាស់ទែងខ្វែងគំនិតគ្នា, រហូតដល់តាំងគុះ ប្រឹក្សានឹងលីសុកអំពីទំនុកដែលក្មេងច្រៀង ។**

---

តាំងគុះនៅស្រុកគៀវហាន់ជាទីក្រុង លុះបានឮថា ស៊ុនកៀនជាចៅហ្វាយស្រុកកាំងតាំងស្លាប់ហើយ មានសេចក្ដីសោមនស្សពន់ពេក ទើបប្រជុំទីប្រឹក្សាហើយថ្លែងសេចក្ដីថា ដែលស៊ុនកៀនស្លាប់នោះ យើងបានធូរស្រាលក្នុងចិត្តច្រើន ទុកមាដូចជាគេដកបន្លាចេញពីដើមទ្រូងនៃយើងបាន, ចុះក្នុងសម័យនេះ នរណាបានដឹងថាស៊ុនកៀនអាយុប៉ុន្មានហើយ? ។ លីយូឆ្លើយថា ស៊ុនកៀននោះទើបនឹងបានអាយុ ៣០ ឆ្នាំគត់ ។ តាំងគុះបានឮដូច្នោះក៏ឃើញថា ស៊ុនកៀននោះនៅក្មេងនៅឡើយ មិនមានសង្ស័យថាដូចម្ដេច ។ ក្នុងខណៈនោះ តាំងគុះក៏កាន់តែមានចិត្តកំរើបឡើង នឹងធ្វើការអ្វីក៏លោភបំពាន.ទៅតាមអំពើចិត្តលើសពីដើម តាំងតំកើងលើកខ្លួនឲ្យមនុស្សទាំងពួងហៅថា "សងអ៊ូ" ប្រែថា

"ព្រះធម្មបិតានៃព្រះចៅហៀនតេ" បើទ្រង់ចេញដំណើរទៅទីឯណា ក៏ឲ្យមានក្បួនហែយ៉ាងព្រះមហាក្សត្រស្តេចយាង ហើយលើកតំកើងតាំងហងជាប្អូនឲ្យធ្វើនាយទាហានកងក្រៅ បណ្តាសែតាំងទាំងប៉ុន្មានក៏ហៅទៅតាំងជានាហ្មឺនតូចធំទាំងអស់, តាំងតុះឲ្យកេណ្ឌរាស្ត្រ ២៥'ម៉ឺនទៅកសាងកំផែង ១ ចម្ងាយពីទីក្រុងតៀវហោន ២៥០០ ស៊ិន (១០០ ក.ម.) ធ្វើកំផែងខ្ពស់ប្រហែលនឹងកំផែងស្រុកក្រុង ខាងក្នុងក៏ឲ្យសង់ដំណាក់តូច-ធំជុំបរិវេណខាងមុខនិងខាងក្រោយ មានទីឃ្លាំងនិងជង្រុកដាក់ស្រូវអង្ករស្បៀងអាហារសម្រាប់សេនាទាហានបរិភោគបាន ២០ ឆ្នាំ ឯមាសប្រាក់ពន្ធដារនិងសួយសារការទាំងប៉ុន្មាន ក៏ឲ្យបញ្ជូនទៅដាក់ឃ្លាំងក្នុងក្រុងថ្មីទាំងអស់ ហើយឲ្យចាត់ស្រីរូបល្អមកបំរុងទុកប្រមាណ ៨០០ នាក់, ឯតាំងតុះជួនកាល ២០ ថ្ងៃ ទើបឡើងទៅគាល់ព្រះចៅហៀនតេម្តង បណ្តានាហ្មឺនតូចធំក្នុងស្រុកក្រុងទាំងប៉ុន្មាន ក៏ត្រូវទៅចាំទទួលឬជូនដំណើរចេញទៅវិញដល់មាត់ទ្វារក្រុង ឯកន្លែងដែលចូលទៅគាល់នោះមានទីប្រថាប់ជាច្រើនដំបន់, ក្នុងស្រុកតៀវហោននោះ ក៏មានទីកន្លែង ១ សម្រាប់សំណាក់នៅតាមត្រូវការ ។ មាន ១ ថ្ងៃនោះតាំងតុះចេញអំពីទីគាល់ បណ្តានាហ្មឺនទាំងពួង ក៏ជូនដំណើរទៅដល់មាត់ទ្វារក្រុង, តាំងតុះទើបបង្គាប់ឲ្យនាហ្មឺនទាំងនោះទៅពិសាលៀងឯទីប្រថាប់ ។

ក្នុងខណៈនោះ ចៅហ្វាយស្រុកមណ្ឌលខាងជើង បញ្ជូនមនុស្សបះបោរប្រហែល ៥០០ នាក់មកដល់តាំងតុះៗ បង្គាប់ទាហានឲ្យយកមនុស្ស

អស់នោះទៅកាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ត្រចៀកខ្លះ កាត់អណ្ដាតខ្លះ ឲ្យស្នោរដាក់ក្នុងខ្លះដែកខ្លះ ៗ មនុស្សទាំងនោះ ក៏មានសេចក្ដីសោយទុក្ខវេទនា នរណាដែលមិនទាន់ដាច់ខ្យល់ស្លាប់ក៏បំរះនរនៀលដោយឈឺចាប់ ស្រែកទ្រហោយំរងំអឺងកង ៗ នាហ្លួនទាំងពួង ដែលកំពុងបរិភោគអាហារបានក្រឡេកទៅឃើញ មានសេចក្ដីអាណិតអាសូរពន់ប្រមាណណាស់ ខ្លះក៏ភ័យស្លុតរបូតបង្កើះធ្លាក់ពីដៃ ខ្លះក៏រង្វើងស្មារតីធ្លាក់កែវស្រាពីដៃកំពប់ស្រាអស់ ព្រោះឃើញសេចក្ដីទុក្ខវេទនាយ៉ាងជាក់ស្ដែងមុខគួរឲ្យកើតធម្មសង្វេគពន់ពេក ៗ ឯតាំងតុៈនោះជាមនុស្សចិត្តអាក្រក់ គ្មានមេត្តាករុណាសោះ លើកតែងស្រាផឹកក្លាង, មើលក្លាង, សើចក្លាង,- មនុស្សទាំង ៥០០ នោះ ក៏ស្លាប់ទាំងអស់គ្នា ៗ នាហ្លួនទាំងអស់បរិភោគអាហារហើយ ក៏លាចុះទៅជាប្រញាប់ ៗ

ក្រោយនោះ តាំងតុៈបង្គាប់លីប៉ោថា យើងនឹងឲ្យអញ្ជើញនាហ្លួនទាំងអស់មកលៀងអាហារម្ដងទៀត បើកាលណាជួបជុំគ្នាហើយចូរកូនឯងទៅនុនខ្សឹបដិតត្រចៀកបិតាចុះ បិតានឹងឲ្យចាប់តៀវអ៊ុនទៅសម្លាប់ចេញ ហើយកាត់ក្បាលយកមក ៗ លុះដល់ថ្ងៃកំណត់ដែលនាហ្លួនទាំងពួងមកស៊ីលៀងអាហារព្រមគ្នាហើយ តាំងតុៈក៏អង្គុយផឹកស្រាតាមធម្មតា ៗ ឯលីប៉ោធ្វើជាចូលទៅនុនខ្សឹបដាក់ត្រចៀកតាំងតុៈៗ ធ្វើជាសើចហើយថា គិតយ៉ាងនេះឬ! ចូលចាប់ខ្លួនវាទៅឲ្យខាប់ ៗ លីប៉ោក៏ស្ទុះទៅចាប់ខ្លួន

តៀវអ៊ុនអូសកន្ទ្រាក់ទៅ ៗ នាហ្មឺនទាំងពួងដែលកំពុងបរិភោគនៅនោះ
មិនដឹងសេចក្តីអ្វីសោះ ទាំងអស់គ្នា ក៏ស្រឡាំងកាំងមួយស្របក់ ស្រាប់
តែឃើញលីហ៊ោយូក្បាលតៀវអ៊ុន ដាក់ក្នុងក្របាស់ ចូលមកឲ្យតាំងតុៈ
មើល នាហ្មឺនទាំងពួងក៏រេតរៃតក់ភ័យណាស់ ៗ តាំងតុៈឃើញដូច្នោះហើយ
ស៊ើបថា អ្នកទាំងអស់គ្នាកុំភ័យប្រារព្ធ, ដែលកើតហេតុទាំងនេះ ព្រោះ
តៀវអ៊ុនឲ្យសំបុត្រស្ងាត់ទៅដល់អ៊ួនស៊ុត ឲ្យមកធ្វើសេចក្តីអន្តរាយដល់
យើងមានគេដឹងរឿងនោះ គេធ្វើសំបុត្រមកឲ្យយើង បានជាលីហ៊ោខ្សឹប
ប្រាប់យើងៗ ទើបឲ្យចាប់ទៅសម្លាប់បេញដូច្នេះ បើអ្នកឯណាមិនបានរួម
គំនិតជាមួយនឹងតៀវអ៊ុននោះទេក៏កុំគប្បីជាទុក្ខ ត្រូវបរិភោគលេងឲ្យ
សប្បាយទៅចុះ ៗ ខណៈកាលនាហ្មឺនទាំងនោះបរិភោគហើយក៏លាទៅ ៗ

ខណៈនោះ មានមន្ត្រីម្នាក់ឈ្មោះអង់អ៊ុន កាលត្រឡប់ទៅដល់ផ្ទះ
ហើយគិតរំពឹងថា រឿងដែលតាំងតុៈឲ្យហៅទៅស៊ីលៀងហើយចាប់តៀវៈ
អ៊ុនសម្លាប់បេញនោះបើនឹងសង្កេតឲ្យឃើញពិតទៅថា តៀវអ៊ុននោះគ្មាន
គិតគំនិតអាក្រក់ ឲ្យសំបុត្រទៅអ៊ួនស៊ុតមកធ្វើសេចក្តីអន្តរាយដល់តាំងតុៈ
សោះទេ តែដែលតាំងតុៈមានសេចក្តីព្យាបាទសម្លាប់គ្នាទាំងម៉្លេះ ក៏គឺធ្វើ
យកអំណាចមិនឲ្យនាហ្មឺនទាំងពួងគិតអាក្រក់នឹងរកតទៅ, ដែលរកធ្វើដូច្នេះ
ក៏មិនមានអ្នកឯណានឹងគិតរំលាងបំផ្លាញរកបេញសោះ ៗ អង់អ៊ុនមាន
សេចក្តីវិតានមិនបានស៊ីដេកជាសុខ លុះដល់ពេលយប់ស្ងាត់ ក៏កាន់ឈើ

ចេញទៅឈរផ្អែកនៅដើមឈើ ១ ក្នុងសួនផ្កា ហើយក្រឡេកមើលទៅលើអាកាស ឃើញផ្កាយរក្សាស្រុកអាប់រស្មីមិនមានពន្លឺ ទើបគេថាសព្វថ្ងៃនេះ ព្រះមហាក្សត្រទ្រង់អាណាប្រជានុរាស្ត្របានសេចក្ដីក្ដៅក្រហាយព្រោះតាំងតុះ ៗ អង់អ៊ុនគិតហើយក៏ដកដង្ហើមធំ ហើយយំខ្សឹកខ្សួល ៗ ក្នុងទីនោះ ស្រាប់តែឮសំឡេងស្រីម្នាក់ទៅដកដង្ហើមធំអំពីខាងមុខអង់អ៊ុនៗ ក្រឡេកទៅឃើញ ក៏ឈ្ងោកមើលមុខស្គាល់ច្បាស់ជានាងគៀវសៀនដែលអង់អ៊ុនលោះយកមកពីតូច ឃើញរូបឆោមល្អៈប្រៀងពីពេះក៏សន្មតទុកជាកូនចិញ្ចឹម នាងនោះក៏ចំរើនអាយុបាន ១៦ ឆ្នាំ ៗ វេលានោះអង់អ៊ុនសួរថា ពេលយប់ជ្រៅនេះហើយម្ដេចមិនទៅដេកចុះមកតែអ្នកក្នុងសួនផ្កានេះ? ហើយដកដង្ហើមធំឬកើតទុក្ខពីព្រោះមិនឃើញសហាយមកជួបឬអ្វី? ៗ នាងគៀវសៀនបានឮដូច្នោះក៏ភ័យស្លុតទន្លុលលុតជង្គង់ហើយជំរាបអង់អ៊ុនថា ខ្ញុំនឹងបានមានសហាយស្មន់ហើយមកនៅចាំជួបដូច្នោះក៏ទេ ខននខ្ញុំជាទាសីលោកៗ ក៏បានបីបាច់ចិញ្ចឹមរក្សាទុកជាកូនតាំងពីតូចមក ព្រះគេជព្រះគុណរកទីបំផុតគ្មាន សព្វថ្ងៃខ្ញុំក៏គិតនៅជានិច្ចថា បើលោកមានសេចក្ដីទុក្ខព្រួយប្រការដូចម្ដេច ខ្ញុំនឹងត្រូវជួយធុរៈនោះទៅតាមសតិបញ្ញា ដើម្បីនឹងបានតបស្នងសងគុណលោក ប្រសិនបើជីវិតខ្ញុំនឹងរលត់ផុតទៅ សាច់ឈាមសរសៃនឹងរលួយនៅផែនដីក្ដី ឆ្អឹងនឹងខ្ទេចខ្ទីជាធូលី ខ្ញុំក៏មិនបានសោកស្ដាយដល់

ជីវិតសោះឡើយ. ពីថ្ងៃព្រឹកមិញដែលតាំងតុៈអញ្ជើញលោកទៅពិសាល្ងៀង ហើយលោកត្រឡប់មកដល់ផ្ទះវិញនោះ ខ្ញុំឃើញទឹកមុខលោកសៅហ្មងប្លែកជាងសព្វថ្ងៃ ខ្ញុំក៏ស្មានថាលោកប្រហែលមានទុក្ខព្រួយអំពីការអ្វីជាទម្ងន់ណាស់ ទើបបានជាប្លែកអស្ចារ្យដូច្នេះ លុះខ្ញុំឃើញលោកអញ្ជើញមកទីនេះខ្ញុំក៏លបបុះមកសង្កេតមើលឲ្យដឹងការ ដើម្បីនឹងជួយរិះគិតជាផ្លូវតបស្នងសងព្រះតេជព្រះគុណត្រាតែអស់ជីវិត ។

អង់អ៊ុនបានឮដូច្នោះក៏គិតថា "គ្រានេះបើផែនដីនឹងបានសុខក្សេមក្សាន្តឡើងវិញ ក៏ដោយសារនាងតៀវសៀនជាប្រាកដ" ទើបនាំនាងតៀវសៀនឡើងទៅលើលានៅក្នុងល្វែងស្ងាត់ ហើយឲ្យនាងអង្គុយលើកៅអីរួចលុតជង្គង់ចុះគំនាបនាង ។ នាងតៀវសៀនឃើញដូច្នោះក៏ភ័យណាស់ ស្ទុះចុះអំពីលើកៅអីមកគំនាប់អង់អ៊ុនវិញ ហើយចូលទៅក្រាបទូលបង្គំទាយាតថា លោកឪពុកមិនត្រូវគំនាប់ខ្ញុំជាកូនទេ ។ អង់អ៊ុនតបថា "ឪពុកបានឮកូនថាអញ្ចឹងមិញនោះ ឪពុកមានសេចក្ដីត្រេកអរណាស់ បានជាឪនគំនាប់កូនៗ ប្ដូរមានមេត្តាករុណា ដល់ព្រះមហាក្សត្រនឹងអាណាប្រជានុរាស្ត្រក្នុងព្រះរាជអាណាខេត្តចុះ" ថាតែប៉ុណ្ណោះហើយក៏យំអោករអ៊ួល ៗ នាងតៀវសៀនបានឃើញបិតាធ្មញយំក៏លើកដៃប្រណម្យជំរាបថា ខ្ញុំបានចេញពាក្យថានឹងយកជីវិតតបស្នងសងគុណលោកឪពុកហើយ ហេតុអ្វីមិនមានប្រសាសន៍ប្រាប់រឿងហេតុដែលកើតទុក្ខនោះឲ្យ

ខ្ញុំដឹង, ដែលលោកឪពុកមកប្រឹងអង្គុយយំដូច្នេះនឹងអស់ទុក្ខហើយឬ? ។ អង់អ៊ុនឆ្លើយថា សព្វថ្ងៃនេះផែនដីក្តៅរំដួលគ្រប់ដើមស្មៅនៅឈើព្រៃទាំងអស់ កូនក៏ល្មមដឹងព្ទណាស់ហើយ ព្រះចៅហ្វៀនគេនោះ ឧបមាដូចពងមាន់ដែលគេចោលទុកលើថ្ម, ឯនាហ្មឺនមុខមន្ត្រីនឹងអាណាប្រជា-នុរាស្ត្រក្នុងព្រះនគរ ឧបមាដូចជាគំនរស្រមាមដែលនៅជិតភ្លើងមិនបានដឹងថាសេចក្តីស្លាប់នឹងមកដល់វេលាណា, តាំងតុះធ្វើការអាក្រក់កំរើកឡើងប្រឹងនឹងយកកពជសម្បត្តិ នឹងរកអ្នកឯណាគិតរំលាងវាចេញគ្មាន ឯតាំងតុះនោះវាមានកូនចិញ្ចឹម ១ ឈ្មោះលីប៉ោ ឯលីប៉ោនោះ ក៏មានថ្វីដៃខ្លាំងពូកែណាស់ តែថាសន្តានចិត្តអ្នកទាំង ២ នេះ រមែងវង្វេងស្រឡាញ់ទៅក្នុងរូបស្រីភាពដែលស្អាតល្អ បើកូននឹងជួយទ្រទ្រង់ផែនដី ឪពុកនឹងគិតឧបាយកលលើកកូនឲ្យទៅធ្វើជាភរិយាលីប៉ោ ហើយទើបទៅប្រាប់តាំងតុះឲ្យមកទទួលកូនយកទៅធ្វើជាភរិយាទៀត បើកូនបានទៅនៅនឹងតាំងតុះវេលាណា ចូរលបធ្វើកលមាយាផ្សេងៗ ឲ្យលីប៉ោមានចិត្តស្នេហ៍ស្រឡាញ់កូនជាប្រាកដ ហើយកូនលបប្រាប់តាំងតុះដោយកលមាយាតាមដំរិះប្រាជ្ញារបស់កូនស្រាប់ យូរទៅឃើញថាតាំងតុះនឹងលីប៉ោមានសេចក្តីបែកចិត្តគិតប្រទូសរ៉ាយគ្នា លីប៉ោគង់នឹងសម្លាប់តាំងតុះចេញ, កាលអាសត្រូវពាលសម្បត្តិវិនាសហើយ អាណាខែត្រទាំងអស់ក្នុងព្រះនគរនឹងបានសេចក្តីសុខតទៅ ឯខ្លួនកូនដែលបានយកអាសាផែនដីនោះ នឹង

មានកេរ្តិ៍ឈ្មោះដរាបរាល់តែអស់អាយុផែនដី ៖ ពុកគិតដូច្នេះតើកូននឹងយល់ព្រមធ្វើតាមដែរឬដូចម្ដេច ? ។

នាងទៀវសៀនឆ្លើយតបថា ខ្ញុំបានចេញពាក្យថានឹងតបស្នងសងគុណលោកឪពុកហើយ ក៏ជាឡើយតែត្រឹមរូបកាយខ្ញុំទៅធ្វើប៉ុណ្ណោះ ទោះបីនឹងប្រើឲ្យទៅស្លាប់ក៏ខ្ញុំមិនស្ដាយជីវិតសង្ខារ វេលានេះបើឪពុកនឹងគិតការយ៉ាងណា ក៏ត្រូវតែគិតលៃលកឲ្យបានស្រេចលាប់ៗ ទៅចុះ បើខ្ញុំបានទៅនៅទីតាំងគុះហើយ ខ្ញុំនឹងធ្វើកលមាយាឲ្យលីប៉ោសម្លាប់តាំងគុះឲ្យបាន ។ អងអ៊ុនតបថា បើកូនបានយកអាសាផែនដីជំនួសឪពុកហើយ - ការអ្វីៗ ដែលកូនគិតនោះត្រូវតែឲ្យជិតកុំឲ្យនរណាដឹងឮមួយជា ២ ឡើយ កូនអើយរឿងនេះបើបែកធ្លាយចេញទៅកាលណា អាយុកូននឹងបាត់មុខជានឹងវិនាសអន្តរាយទៅវិញមុខជាប្រាកដ ។ នាងទៀវសៀនបានស្ដាប់ច្បាស់ក៏ឆ្លើយថា សេចក្ដីនេះបើខ្ញុំមិនបិទបាំងតាំងធ្វើឲ្យបែកធ្លាយហើយ ខ្ញុំសូមឲ្យត្រូវប្រហារដោយអាវុធផ្សេងៗចុះ ។ អងអ៊ុនបានឮពាក្យនាងដំណាលដូច្នោះហើយ ក៏មានសេចក្ដីសោមនស្សត្រេកអរពន់ពេក ។ លុះដល់ព្រឹកឡើង អងអ៊ុនក៏បាត់បែងរើយកត្បូងពេជ្រនឹងមាសប្រាក់មកទុក ហើយហៅជាងមកធ្វើជាម្កុដសម្រាប់បុត្រព្រះមហាក្សត្រទ្រង់ពាក់ លុះធ្វើស្រេចហើយ ក៏ប្រើមនុស្សទំនុកទុកចិត្តឲ្យលបយកទៅឲ្យលីប៉ោៗ ឃើញម្កុដវិសេសដូច្នោះទទួលយកហើយដោយសេចក្ដីពេញចិត្ត លុះដល់ថ្ងៃក្រោយលបមកជួបនឹងអងអ៊ុននៅផ្ទះ ។ (មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

---

**ការកសាង**: ព្រះបាទសូរ្យវរ្ម័ន ទី ១ ទ្រង់បានសាងវត្តស្ថាន សម្រាប់ព្រះសាសនា និងសម្រាប់រាជការផែនដីជាយ៉ាងច្រើន, ប្រាកដតាមដែលស្រាវជ្រាវក្នុងវេលានេះ គឺ: ទ្រង់សាងវត្ត ១ នៅក្នុងកំពែងក្រុងយសោធរបុរៈ ឲ្យឈ្មោះថា "សោគតាស្រម" (អាស្រមព្រះសុគត) គឺវត្តដែលគេហៅក្នុងកាលឥឡូវនេះថា "ទេពប្រណម្យ" សឹងមានព្រះពុទ្ធរូបព្រះធំ ១ អង្គ, សន្ធឹកសីមាថ្មជាច្រើន និងសិលាចារឹក ១ ផែនទៀត នៅក្នុងបរិវេណវត្តនេះជាភស្តុតាង ។ ទាំងទ្រង់បដិសង្ខរណ៍ប្រាសាទទេវស្ថាននៅលើកំពូលភ្នំបាខែង ដែលបានសាងឡើងតាំងពីក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ គឺទ្រង់បានជួសជុលក្នុងផ្នែកខ្លះដែលបាក់បែកទ្រុឌទ្រោម និង ទ្រង់កសាងថែមឡើងទៀតខ្លះ និង ទ្រង់រៀបចំធ្វើផ្លូវសម្រាប់ឡើងទៅកំពូលភ្នំនេះ ឲ្យបានស្រួលជាងមុន ព្រោះ

គឺនេះជា **គារវិស្ថាន** ឬជា **បូជនីយស្ថាន** របស់ព្រះមហាក្សត្រិយ៍ទាំងឡាយបណ្ដាដែលគង់នៅក្រុងយសោធរបុរៈនេះ ៗ រូបពីនេះស្ដេចបានទៅសាងប្រាសាទទេវស្ថាននៅក្នុងដីស្រុក ក្នុងខែត្របាទី សម្រាប់សាធារណជនគោរពបូជា, ប្រាសាទទេវស្ថាននេះគង់រូបរាងនៅដល់សព្វថ្ងៃនេះ ៗ

ក្រៅអំពីនេះ ព្រះអង្គបានទៅសាងនៅតាមបច្ចន្តរដ្ឋជាច្រើនអន្លើទៀត, ចំពោះក្រុងយសោធរបុរៈនោះប្រាកដថា ជាទីសព្វព្រះរាជហឫទ័យច្រើន តែស្ដេចយាងទៅសម្រាកព្រះកាយនៅទីនោះជាញឹកញយ ទ្រង់បានចាប់ចាត់ការរៀបចំតាំងពីក្រោយពេលដែលព្រះបាទអនុរុទ្ធគិតលើកមករាយ គឺទ្រង់ពង្រីកទីក្រុងឲ្យធំទូលាយចេញទៅ ទ្រង់សាងព្រះរាជវាំងកំពែង-ប៉មយ៉ាងមាំមួន សម្រាប់ការពារសឹកមកពីក្រៅ ទ្រង់សាងថ្នល់-ស្ពានជាច្រើនអន្លើទៀត ៗ និងទ្រង់សាងវត្តស្ថានក្នុងសាសនាទៀតជាយ៉ាងច្រើន ព្រះពុទ្ធរូប គឺព្រះស្ដូបចេតិយ វត្ត វិហារ, ព្រះទេវរូប ព្រះប្រាង្គសិលាកំពូលបី និង សិលាចារិក ៗ បុរាណវត្ថុស្ថានអំពាលនេះនៅគង់មានរូបរាងជាភស្ដុតាងដល់សព្វថ្ងៃនេះជាច្រើន ៗ ព្រះប្រាង្គនោះធំជាងព្រះប្រាង្គដែលសាងទុកនៅតំបន់ដទៃទាំងអស់, នេះជាអនុស្សាវរីយក្នុងសម័យដែលខ្មែរជាធំក្នុងដែនខ្មែរទាកាតែ ៗ

លំដាប់តពីនេះ បានស្តេចទៅសាងក្រុងកំពែងពេជ្រនៅក្នុងរដ្ឋ ដលៀង ហើយប្រហែលផ្លាស់ឈ្មោះក្រុងនេះហៅថា **នគរកោសម្ពិ** ក្នុងពេលនេះផង ព្រោះទីនោះមានសណ្ឋានភូមិភាគប្រហែលគ្នានឹងនគរកោសម្ពី ក្នុងមជ្ឈិមប្រទេស ។ តែសព្វថ្ងៃនេះ គេច្រើនហៅកំពែងពេជ្រតាមដើម ។

ចំណែកឯព្រះកំស្តេងអញស្រីជយេន្ទ្របណ្ឌិត ក៏បានកសាងវត្ត-ស្ថានក្នុងសាសនា និងរបស់ជាសាធារណប្រយោជន៍មានជីកស្រះ ជីកអណ្តូង ធ្វើទំនប់ទឹក ។ល។ ជាច្រើនណាស់ដូចមានប្រាកដនៅសិលាចារឹក ក្នុងស្តុកកុម្ពស្រាប់ ។

ព្រះបាទសូរ្យវរ្ម័ន ទី ១ ស្តេចនៅក្នុងរាជសម្បត្តិបាន ៣៨ ឆ្នាំ ក៏សោយទិវង្គត រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា **បរមនិព្វាណបទ** ( បរមនិព្វានបទ ) ដោយហេតុទ្រង់និយមក្នុងព្រះពុទ្ធសាសនាជាសំខាន់ក្នុងព្រះរាជហឫទ័យ ។

ទ្រង់មានព្រះកិត្តិយសជា រាជាធិរាជ ១ អង្គក្នុងប្រវត្តិសាស្ត្រ ។

## ព្រះបាទឧទយាទិត្យវរ្ម័ន ទី ២

ព. ស. ១៥៩៣ - ១៦០៨, គ. ស. ១០៥០ - ១០៦៦

ព្រះឧទយាទិត្យវរ្ម័ន ជាព្រះរាជឱរសរបស់ព្រះបាទសូរ្យវរ្ម័ន ទី ១ និងព្រះនាង វីរលក្ស្មី អគ្គមហេសី, ទ្រង់ប្រសូតក្នុងសករាជប៉ុន្មានមិន

ប្រាកដ ទ្រង់បានសិក្សាវិជ្ជាគ្រប់យ៉ាង មានដើមថា សិទ្ធាន្ត, វ្យាករណ៍, ធម៌សាស្ត្រ និងសាស្ត្រឯទៀតៗ ក្នុងសំណាក់ព្រះរាជគ្រូ ស្រីជយេន្ទ្របណ្ឌិត ។ កាលព្រះរាជជនកនាថសោយទិវង្គតហើយ ទ្រង់បានទទួលគ្រងរាជសម្បត្តិស្នងព្រះអង្គតមក. គេថ្វាយព្រះបរមនាមថា ព្រះបាទឧទយាទិត្យវរ្ម័ន រាប់ជាទី ២ ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដួចម្តេចមិនប្រាកដ តែទ្រង់គ្មានព្រះរាជឱរសព្រះរាជធីតាទេ ។

**ការផែនដី:** ការគ្រប់គ្រងផែនដីក្នុងរដ្ឋកាលនេះមិនប្រាកដថាខូចខាតផែនដីក្នុងភាគណាមួយទេ តែក្រោយដែលទ្រង់សោយរាជ្យបាន ១ ឆ្នាំ គឺក្នុងឆ្នាំ ព ស ១៥៩៤ មានរាជសត្រូវឈ្មោះ អាណាវិន្ទ្ររាជ បរមសេនាទាហានបង្កហេតុបះបោរឡើង ក្នុងព្រះរាជអាណាចក្រដើម្បីរាជបល្ល័ង្ក, ព្រះបាទឧទយាទិត្យវរ្ម័នទ្រង់ជ្រាប ក៏ត្រាស់ឲ្យសេនាបតី ១ នាក់ ឈ្មោះ ព្រះសង្គ្រាម (គឺជាសេនាបតីក្រសួងសឹក) ឲ្យលើកទ័ពចេញទៅក្រាប, កងទ័ពទាំងពីរខាងបានតស៊ូគ្នាពេញទំហឹង តែក្នុងទីបំផុតអាណាវិន្ទ្ររាជបរាជ័យ ហើយរត់ទៅជ្រកនៅក្នុងចម្ប៉ា (ចាម្ប៍) បាត់ទៅ ។

លុះកន្លងមកដល់ឆ្នាំ ព. ស. ១៦០៩ (ម. ស. ៩៨៨) មានមន្ត្រី ១ នាក់ជាទាហានរបស់ព្រះអង្គ ឈ្មោះកាមភវៈ ជាទីប្រោសប្រាណរបស់ព្រះអង្គ បានក្រាបទូលញុះញង់ឲ្យទ្រង់ដកសេនាបតី ១ នាក់

អ្នកមានអាយុខ្ពស់ ចេញពីតំណែងកងការ ដោយបំណងនឹងចូលកាន់តំណែងនោះដោយខ្លួនឯង ។ ព្រះបាទឧទយាទិត្យវរ្ម័ន ពុំព្រមតាម ។ កាមភារៈ ទោមនស្សផងភ័យខ្លួនផង ក្រែងព្រះមហាក្សត្រិយ៍រករឿង ក៏នាំពួកទាហានដែលនៅក្នុងបន្ទាយរបស់ខ្លួនចេញទៅខែត្រក្រៅ ហើយបញ្ចុះបញ្ចូលកស្តុបក្កដាទ័ពនាំបះបោរឡើង ព្រះមហាក្សត្រិយ៍ទ្រង់ជ្រាប ក៏ត្រាស់ចាត់មេទ័ព ១ នាក់ឲ្យលើកទ័ពចេញទៅកម្រាប តែមេទ័ពនោះតស៊ូពុំបាន ក៏បរាជ័យក្ស័យជីវិតបង់ ។ កាលព្រះមហាក្សត្រិយ៍ទ្រង់ជ្រាបពត៌មានសឹកដូច្នេះហើយ ក៏ទ្រង់ព្រះរាជបញ្ជាក្សត្រិយ៍សឹក (1) (សេនាប្រមុខ) ១ នាក់ ដែលធ្លាប់មានថ្វីដៃ ឲ្យនាំទ័ពចេញទៅកម្រាប ។ វេលាដែលក្សត្រិយ៍សឹកនេះទៅដល់តស៊ូគ្នានោះ មានមេកង ១ នាក់ខានខ្លាំង បានចាក់ត្រូវក្សត្រិយ៍សឹកធ្លុះបន្លា, ព្រះក្សត្រិយ៍សឹកនោះទោះបីត្រូវរបួសម្ល៉ោះហើយក៏ដោយ ក៏មិនរាថយបានបែរតស៊ូតទៅទៀតយ៉ាងអង់អាច គឺលោកប្រើធ្នូរបស់លោកបាញ់ចេញទៅយ៉ាងញឹក កូនសរបានរត់ទៅត្រូវត្រង់ក្បាលកាមភារៈ ១ អន្លើ ទឹងត្រង់ក ១ អន្លើទៀត; កាមភារៈ ទ្រាំរបួសពុំបាន ក៏ដួលគ្រងចាំងគ្រៀងការុង ដែលកាន់នៅដៃ មិនយូរប៉ុន្មានក៏អស់ខ្យល់អស្សាសៈបស្សាសៈទៅតាមយថាកម្ម ។

---

១ ក្សត្រិយ៍សឹកនេះ ប្រហែលជាព្រះសង្គ្រាម ដែលជាសេនាបតីទាហាន ។ ។

កាលស្រេចកិច្ចក្រាបសឹកសត្រូវហើយ លោកក្សត្រិយ៍សឹកក៏រៀបចំខែត្រនោះ (មិនដឹងច្បាស់ជាខែត្រណា) ឲ្យរៀបរយដូចដើមហើយ ទើបបានលើកទ័ពត្រឡប់ចូល ក្រុង ។ កាលមកជិតដល់ក្រុង ក៏មានឧប្បត្តិហេតុ ១ ជាថ្មីទៀតមកប៉ះពាល់ ក៏មានបងប្អូនពីរនាក់ ឈ្មោះស្វាត ស្អាត់? ១ ឈ្មោះ សិទ្ធិករ ១ បានលើកគ្នាមកចាំប្រទូសរ៉ាយ លោកក្សត្រិយ៍សឹកបានបញ្ជាឲ្យទាហានបោះពួនចាប់បានម្រិតទាំងពីរ តែក ហែកចំណោមចេញរួចទៅ បានទាំងសម្លាប់ទាហានរបស់លោកអស់ជាច្រើនផង ។ លោកក្សត្រិយ៍សឹកក្រោធក៏ចេញដេញច្បាំងដោយខ្លួនឯង ចាប់បានគូខាំងទាំងពីរប្រហារជីវិតបង់[១] ហើយលោកនាំទ័ពចូលក្រុង ។ អំពីនោះប្រទេសក៏បានសាន្តត្រាណជាប្រក្រតី ។

**ការសាសនា** : ព្រះបាទឧទយាទិត្យវរ្ម័នទ្រង់រាប់អានទាំងសាសនាព្រាហ្មណ៍ទាំងព្រះពុទ្ធសាសនា តែទ្រង់និយមខាងសាសនាព្រាហ្មណ៍ ដែលជាសាសនាសម្រាប់ដេកងសម័យនោះធ្ងន់ជាង ទ្រង់បានតាំងស្តេងអញ ស្រីជយេន្ទ្របណ្ឌិត ជារាជបុរោហិតចាស់តាំងពីរជ្ជកាលព្រះរាជបិតាមក ហើយជាព្រះរាជគ្រូរបស់ព្រះអង្គផងនោះ ជាទីប្រឹក្សាការផែនដី និងធ្វើពិធីផ្សេងៗ ថ្វាយតាមទំនៀម ទ្រង់គោរពព្រះមហារាជគ្រូនេះខ្លាំងណាស់ [illegible] បានទ្រង់ព្រះមេត្តាតាំងឲ្យឡើងយសសក្តិជា "ព្រះកម្រតេង

---

១ រឿងក្បត់នេះគេឃើញប្រាកដនៅសិលាចារឹក ដែលប្រតិស្ឋានទុកនៅវត្តព្រះគោក ក្នុងកំពែងព្រះមហានគរ ។

អញ ស្រីជយេន្ទ្រវរ្ម័ន" មានយសសក្តិធំជាងរាជបុរោហិតក្នុងរជ្ជកាលមុនទាំងអស់ ការស្តីនិយាយតោងប្រើរាជស័ព្ទដូចជាស្តេច ៗ រាជបុរោហិតនេះហើយដែលបានសាងសិលាចារឹកនៅស្តុកកុម្ព និយាយរៀបរាប់រឿងរ៉ាវតាក់តាមដោយព្រះរាជពង្សាវតារ តាំងពីរជ្ជកាលព្រះបាទជយវរ្ម័នទី ២ រៀងមកដល់ផុតរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័នទី ២ នេះ ហើយលោកស្លាប់ក្នុងរវាងរជ្ជកាលនេះ ។

ក្នុងរជ្ជកាលនេះមានសេនាបតីធំ ១ នាក់ ងារជា "ព្រះសេនាបតីសង្គ្រាម" ជាអ្នកមានថ្វីដៃក្នុងការសង្គ្រាមធ្លាប់មានជ័យជំនះមក។ហើយជាអ្នកកាន់ព្រះពុទ្ធសាសនា បានសាងវត្តដែលពាក្យសាមញ្ញហៅ "ព្រះងោក" នៅក្នុងកំពែងក្រុងស្រីយសោធរបុរៈ នៅជាខាងលិចប្រាសាទយសោធរគិរី (បាយ័ន) មានធីតា ១ នាក់ ឈ្មោះ នាង ១បា ជាអ្នកកាន់ព្រះពុទ្ធសាសនាបែបយ៉ាងបិតា ។

ការព្រះពុទ្ធសាសនាដែលប្រាកដក្នុងប្រវត្តិសាស្ត្រ ហើយដែលយើងត្រូវទុកជាសំខាន់បំផុតមួងទៀត គឺក្នុងរជ្ជកាលនេះ ក្រោយដែលព្រះអង្គសោយរាជ្យបាន ៣ ឆ្នាំ ក៏ទទួលបានគម្ពីរព្រះត្រៃបិដក និងព្រះពុទ្ធរូបព្រះកែវមរកត[១] ដែលខ្វាត់ខ្វាត់បួលមកក្នុងព្រះរាជអាណាចក្រ (ក្នុងឆ្នាំ ព. ស. ១៥៩៦) ។

---

១ ប្រវត្តិព្រះកែវមរកតមានសេចក្តីពិស្តារនៅក្នុងរតនពិម្ពវង្ស ។

រឿងព្រះត្រៃបិដក និង ព្រះកែវមរកតដែលក្លាត់មកប្រទេសកម្ពុជា នេះ ប្រាកដក្នុងព្រះរាជពង្សាវតារថា: ព្រះបាទអនុរុទ្ធ ក្សត្រិយ៍ភូមា សោយរាជសម្បត្តិនៅក្រុងភុកាម (បុណ្ណកាម) ក្នុងរវាង ព. ស. ១៥៥៣ ដល់ ១៥៩៥ ព្រះអង្គជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានព្រះរាជប្រាថ្នាយ៉ាងខ្ពស់ក្នុងការទំនុកបម្រុងព្រះពុទ្ធសាសនា ៗ គ្រាមួយនោះ ព្រះអង្គបានផ្ញើអ្នកប្រាជ្ញទាំងអ្នកដែលជំនាញការសរសេរបារ ក្នុងសំពៅធំ ២ ហើយបើកសំពៅទៅលង្កា ដើម្បីចំលងគម្ពីរព្រះត្រៃបិដក ៗ កាលចំលងចប់ហើយទ្រង់បានសូមយកព្រះកែវមរកត អំពីព្រះបាទលង្កិស្សរាជ (ព្រះរាជាក្រុងលង្កា) មកផង ទ្រង់ឲ្យផ្ទុកគម្ពីរព្រះត្រៃបិដកនឹងព្រះកែវមរកតក្នុងសំពៅ ១ ហើយឲ្យរាជបរិពារខ្លះជិះក្នុងសំពៅនោះ, ចំណែកព្រះអង្គគង់ក្នុងសំពៅ ១ ទៀតជាមួយរាជបរិពារខ្លះ បើកត្រឡប់ព្រះនគរវិញ លុះបើកផុតកោះម៉ាលកាមកហើយ ក៏បត់បែរមកទិសខាងជើងសំពៅមកប្រទេសភូមា តែដល់វេលានោះ មានខ្យល់ព្យុះខ្លាំង បោកផាត់សំពៅដែលផ្ទុកព្រះត្រៃបិដកនឹងព្រះកែវមរកត រសាត់ជ្រុលចូលមកដល់ប្រទេសកម្ពុជា គឺចូលមកត្រង់ឆ្ងាយទៃក្រប៉ខ្ទាយមាសខាងត្បូង (ត្រង់ហាវៀង) អ្នករាជការនៅត្រង់នេះចាប់បាន ក៏នាំទៅថ្វាយព្រះករុណាព្រះបាទទុទយាទិត្យវរ្ម័ន ទ្រង់មានព្រះរាជហឫទ័យសោមនស្សខ្លាំងណាស់ ៗ

(មាន)

## សាវតារវត្តអង្គារស

### នៅលើកំពូលភ្នំព្រះរាជទ្រព្យ ស្រុកឧដុង្គ ខែត្រកណ្ដាល

# អ្នកអង្គម្ចាស់ក្សត្រី នរោត្តម-សុខាតារី

ធ្វើការនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

(រង្វាន់លេខ ២)

---

ប្រទេសកម្ពុជាយើងទាំងមូល គេតែងធ្វើព្រះវិហារបែរមុខឆ្ពោះទៅទិសខាងកើតទាំងអស់ ពុំដែលមាននរណាមួយធ្វើវត្តធ្វើព្រះវិហារបែរមុខទៅទិសដទៃឯទៀតឡើយ ។ សេចក្ដីនិយមប្រកាន់តាមទំនៀមទម្លាប់អំពីបូរាណមកនេះ ព្រោះគេយល់ឃើញថា ព្រះពុទ្ធអង្គកាលនៅវេលាដែលទ្រង់បានត្រាស់សម្មាសម្ពោធិញ្ញាណ ទ្រង់គង់បែរព្រះភក្ត្រឆ្ពោះទៅទិសខាងកើត ។

ប៉ុន្តែអ្នកទាំងឡាយបានសង្កេតឃើញទេ? នៅក្នុងប្រទេសខ្មែរយើងទាំងមូល មានតែព្រះវិហារមួយទេដែលគេធ្វើបែរមុខឆ្ពោះទៅទិសខាងជើង ដែលអ្នកស្រុកយើងពុំធ្លាប់និយមធ្វើយ៉ាងនេះសោះ ។ ព្រះវិហារនោះ ឈ្មោះថា "អង្គារស" សាងនៅលើកំពូលភ្នំព្រះរាជទ្រព្យ ក្នុងស្រុកឧដុង្គ ខែត្រកណ្ដាល ។ សេចក្ដីចំឡែកប្លែកអស្ចារ្យនេះហើយ ដែលនាំឲ្យខ្ញុំកើតអំពល់រវល់នៅពុំសុខដើរស៊ើបសួរអ្នកដែល

ខ្ញុំស្គាល់តាំងពីប៉ុន្មាន ដែលធ្លាប់ស្គាល់ថាជាអ្នកបេះដូងខាងទំនៀមទម្លាប់របស់ខ្មែរយើងអំពីបុរាណ ហើយមិនយូរប៉ុន្មាន ខ្ញុំក៏បានដឹងដូចបំណង ។

អ្នកព្រឹទ្ធាចារ្យដែលបុរេនិទានរឿងនេះប្រាប់ខ្ញុំ គឺជាព្រះរាជវង្សា-នុវង្សមួយព្រះអង្គទ្រង់ជរាណាស់ទៅហើយ កាលពីដើមទ្រង់គង់នៅភ្នំពេញដែរ តែក្នុងរាជ្យប៉ុន្មានឆ្នាំនេះ ទ្រង់ស្ដេចទៅគង់នៅឧដុង្គ ។ កាលពីដើមទ្រង់ធ្លាប់ស្គាល់តែសេចក្ដីរុងរឿង សេពគប់តែនឹងចំណោមធំ គាល់បំរើព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ យ៉ាងជិតដិតញឹកញាប់ ហើយធ្លាប់ស្ដេចទៅមករាប់អាននឹងមន្ត្រីធំៗ រដ្ឋមន្ត្រីឯទៀតជាច្រើន ៗ ហេតុដែលខ្ញុំមិនបញ្ចេញព្រះនាមនេះ ដោយទ្រង់ពុំយល់ព្រមផង ។ ទ្រង់សព្វព្រះទ័យតែសេចក្ដីស្ងប់ស្ងាត់ពុំឲ្យមានអ្នកណាទៅរកគួររំខានដល់ទ្រង់ឡើយ ។ សេចក្ដីដែលមានតទៅនេះ គឺជាព្រះបន្ទូលរបស់ទ្រង់ :

កាលនៅក្នុងសតវត្សរ៍ ១៣ គឺនៅក្នុងសម័យអង្គរ ព្រះចៅប្រទេសចិនទ្រង់បានចាត់បេសកជនជាច្រើនក្រុមឲ្យដើរមើល ស៊ើបសួរក្នុងប្រទេសនានា តើបណ្ដានគរមានអារ្យធម៌របៀបណាខ្លះ ។ បើអារ្យធម៌ប្រទេសណាចំរើនរុងរឿងនោះ ត្រូវលួចកត់យកមកប្រតិបត្តិផ្សាយក្នុងប្រទេសចិន. ឬប្រទេសចិននឹងសុំចងសម្ពន្ធមិត្តនឹងប្រទេសនោះ ។

បើប្រទេសណាហើយប្រកបដោយនូវការប្រធម៌ដ៏ខុសអាប់ ប្រទេសចិននឹងគិតទំនុកបំរុងប្តូរមួយយកធ្វើជាប្រទេសចំណុះ ។

កាលនោះ ក្រុមបេសកជនចិន បានចូលមកមើលស៊ើបសួរគ្រប់ប្រទេសខ្មែរយើងសព្វគ្រប់ហើយ ក៏ត្រឡប់ទៅទូលព្រះចៅក្រុងចិនវិញថា "ប្រទេសខ្មែរជាប្រទេសចំរើនរុងរឿងមានឥទ្ធានុភាព តែឥឡូវនេះចុះអាប់ឱនជាងកាលពីមុនបន្តិចហើយ, អ្នកស្រុកនៅដើរជើងទទេ, បរិភោគអាហារនឹងដៃ, ក្បាលទទេ, ពុំសូវឃើញមានប្រើប្រាស់អ្វីឲ្យបានងាយស្រួលទេ, ប៉ុន្តែមិនយូរប៉ុន្មានទេ ប្រទេសខ្មែរមុខជានឹងជួបប្រសព្វនឹងសេចក្តីចំរើនឡើងវិញលើសដើមជាអស្ចារ្យ" ។ ព្រោះថាពួកបេសក-ជនទាំងនោះបានមកឃើញទីមួយកន្លែង ដែលតាមក្បួនចិនសែថា ទីកន្លែងនោះអាចនឹងឲ្យផលល្អផ្សេងៗដល់ប្រទេស ។ ទីកន្លែងនុ៎ះ គឺភ្នំព្រះរាជទ្រព្យយើងសព្វថ្ងៃ ដែលនៅក្នុងស្រុកខ្ពង់ ។ ពួកបេសកជនបានមើលឃើញភ្នំនេះមានរាងដូចជាសត្វមករ គឺខ្លួនសត្វមករនៅត្រង់បេតំយក្រៃត្រឹង្ស, ក្បាលនឹងពុកមាត់មករនៅត្រង់បេតំយទទឹម, រីឯកន្ទុយមករនៅត្រង់ព្រះពុទ្ធរូបចូលនិព្វាន ។ មិនត្រឹមតែប៉ុណ្ណោះទេ នៅលើកំពូលភ្នំថែមទាំងមានរូងមួយធំជ្រៅស្រឡូងចុះទៅក្រោមផង ។ ពួកចិនយល់ឃើញថា មិនយូរប៉ុន្មានសត្វមករនឹងកំរើកចេញមកតាមរូងនេះ ហើយតាមក្បួនចិនសែថា បើប្រទេសឯណា ឬ ទីឯណាមានសត្វមករផុះឡើង

ប្រទេសនោះទីនោះ  នឹងមានរដ្ឋអំណាចថ្កុំថ្កើងរុងរឿងអស្ចារ្យ  ពុំមានប្រទេសឯណាអាចនឹងតស៊ូបានឡើយ ៗ  ដូច្នេះ  ដើម្បីជាសេចក្ដីសុខដល់ប្រទេសចិនទៅអនាគត  មន្ត្រីចិនទាំងឡាយទូលស្ដេចចិនសូមឲ្យលើកទ័ពមកវាយយកប្រទេសខ្មែរធ្វើជាចំណុះឲ្យហើយ ៗ ស្ដេចចិនទ្រង់ព្រះតំរិះថា  ធ្វើយ៉ាងនេះឃើញដូចជាលោភលើប្រទេសខ្មែរពេកណាស់, ម្យ៉ាងទៀតប្រទេសខ្មែរនៅខ្លាំងពូកែថ្កុំថ្កើងនៅឡើយ  ប្រទេសចិនពុំអាចនឹងវាយយកបានដោយងាយទេ  បើទោះបីប្រទេសខ្មែរគង់តែច្បាំងចាញ់ប្រទេសចិនក៏ពិតមែនហើយ  ប៉ុន្តែប្រទេសចិនមុខជាលំបាកវេទនាខ្លួនអស់ពលយោធា  មានទុក្ខវេទនាដល់បណ្ដាជនមិនខានឡើយ ៗ ដូច្នេះ, ស្ដេចក្រុងចិនទ្រង់ព្រះតំរិះរកកលឧបាយផ្សេងៗ ទៅវិញ ៗ

ដំបូងឡើង, ដើម្បីនឹងបង្រាបកុំឲ្យប្រទេសខ្មែរបានលូតលាស់តទៅទៀត,  ពួកចិនគិតសង្កប់រូងភ្នំនោះឲ្យជិត  កុំឲ្យសត្វមករចេញមករួច ៗ បើយកដុំថ្មសង្កប់រូងនោះ  ខ្លាចក្រែងថ្ងៃក្រោយមកខ្មែរយល់គំនិតនឹងគាស់ចេញវិញបាន ៗ បើដូច្នេះ ពួកចិនស៊ើបទៅឃើញថា ប្រទេសខ្មែរកាន់ព្រះពុទ្ធសាសនាមុតមាំណាស់  នៅទីឯណាដែលមានព្រះពុទ្ធរូប, មានព្រះវិហារ  ខ្មែរពុំហ៊ានទៅរំលោភរំលើងទីនោះទេ  ៗ  ដោយហេតុនេះហើយបានជាស្ដេចក្រុងចិន  ឲ្យមន្ត្រីចិនមកសុំធ្វើព្រះវិហារនៅលើកំពូលភ្នំនេះ ៗ

ដំបូង,ពួកចិនឆ្លាក់សាងព្រះពុទ្ធរូបមុនគេ  រួចតមក  ទើបបានធ្វើព្រះវិហារនឹងសីមាតាមទម្លាប់ទំនៀមអ្នកស្រុក  ព្រមទាំងតាមក្បួនហោរ-

សាស្ត្រចិនផង ហេតុនេះហើយបានជា ព្រះវិហារនោះបែរមុខឆ្ពោះទៅទិសខាងជើង គឺឆ្ពោះទៅរកប្រទេសចិន ។ នាមព្រះវិហារ យើងពុំដឹងជាពួកចិនឲ្យឈ្មោះដូចម្ដេចទេ តែជនជាតិខ្មែរ ដោយឃើញព្រះពុទ្ធរូបធំអស្ចារ្យមានកំពស់ ១៨ ហត្ថ ក៏នាំគ្នាហៅថា "ព្រះវិហារ អដ្ឋារស" ។ តមកស្ដេចក្រុងចិនឲ្យមន្ត្រីចិននាំប្រស្នា ៣ ខមកថ្វាយព្រះរាជាប្រទេសខ្មែរដោះស្រាយ បើដោះស្រាយប្រស្នាទាំ ៣ នេះពុំបាន នោះប្រទេសខ្មែរត្រូវទៅចំណុះប្រទេសចិន ត្រូវយកសួយសារអាករទៅថ្វាយស្ដេចក្រុងចិនរាល់ឆ្នាំ ។ ឯប្រស្នារបស់ស្ដេចក្រុងចិនទាំង ៣ នោះ ដូចមានតទៅនេះ

ដំបូង, មន្ត្រីចិនម្នាក់ដែលជាអ្នកនាំប្រស្នាពីស្ដេចក្រុងចិន មកថ្វាយស្ដេចខ្មែរឲ្យដោះស្រាយនោះ ក្រោកឈរឡើងចំពោះព្រះភក្ត្រព្រះរាជានូវអស់មន្ត្រីខ្មែរទាំងឡាយ ហើយធ្វើអាការដូចតទៅនេះ ។

ប្រស្នាទី ១ មន្ត្រីចិនចំកោងខ្នង លាដៃទាំងពីរ ធ្វើរបៀបដូចឧបរបស់អ្វីយ៉ាងធំ ។

ប្រស្នាទី ២ មន្ត្រីចិនក្ដាប់ដៃម្ខាង លើកឡើងកំពស់មុខ ។

ប្រស្នាទី ៣ មន្ត្រីចិនបោះដៃម្ខាងត្រង់ទៅមុខ ហើយលាម្រាមដៃទាំង ៥ ត្រង់ ។

ហើយថ្វាយកាលកំណត់ស្ដេចខ្មែរថា ៧ ថ្ងៃទៀតឡប់មកគាល់សុំព្រះរាជទានសេចក្ដីដោះស្រាយ ។ (មានត)

# ប្រវត្តិរបស់អេសុប

## លោក ផេង-ជ្រឹវ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារីភ្នំពេញ

ប្រែរៀបរៀង

---

អេសុបជាកវីជាតិក្រិក កើតនៅដែនហ្វ្រីស៊ី (phrygie) ក្នុងភូមិមួយឈ្មោះអាមូរីយុម (Amorium) ប្រហែលជាពីររយឆ្នាំ ក្រោយការកើតឡើងនៃនគររ៉ូម (Rome) បើគិតទៅត្រូវជា ១៤៦ ឆ្នាំ ក្រោយព្រះពុទ្ធយើងបានត្រាស់ ហើយត្រូវជា ៥៥៤ ឆ្នាំមុនកំណើតនៃព្រះគ្រិស្ត ។

អេសុប គេមិនដឹងជាលោកត្រេកអរឬតូចចិត្តនឹងវាសនារបស់លោកឬដូចម្តេច? ព្រោះគំនិតនឹងប្រាជ្ញារបស់លោកមានបរិបូណ៌ ប៉ុន្តែកាយរបស់លោកវិកលវិការ មុខអាក្រក់ ស្ទើរតែមិនមែនជាមុខមនុស្សដូចគេពល់គ្នា ហើយលោកថែមទាំងជំទ្បាន់ផង ។ បើយ៉ាងដូច្នេះ ក្រៅតែពីនៅនៅស៊ីឈ្នួលអ្នកដទៃ លោកមិនដឹងនឹងរកអ្វីចិញ្ចឹមខ្លួនបានឡើយ, តែទោះបីយ៉ាងដូច្នេះក៏ដោយ ចំណែកចិត្តរបស់លោកតាំងនៅមាំជាចិត្តសេរី ជាចិត្តគ្មានជាប់ចំពាក់នឹងវត្ថុអ្វីៗ ទាំងពួងក្នុងលោក ។

ចៅហ្វាយនាយរបស់លោក ដើមដំបូង បញ្ជូនលោកឲ្យទៅភ្ជួរដីឯចំការ, ដែលគេឲ្យទៅដូច្នេះ ប្រហែលជាគេគិតថាលោកមិនប្រសប់ខាងការផ្ទះ ឬមួយគេឲ្យចេញឲ្យតែបាត់ពីមុខគេ ដ្បិតរូបលោកអាក្រក់ពេក ។ ពេលមួយចៅហ្វាយរបស់លោកនៅឯចំការ, មានអ្នកស្រែម្នាក់យកផ្លែក្រខុបមក

ជូន ១ លោកកុដុម្ពិក៍ឃើញផ្លែឈើល្អពេញចិត្ត ក៏ប្រាប់ឲ្យបាវម្នាក់ឈ្មោះ អាគាថូពុះ (Agathopus) យកទៅទុកដាក់ឲ្យស្រួល លុះកាលណាលោក ងូតទឹកហើយ ឲ្យយកមកជូនលោកបរិភោគ ។ ទេសកាលអី ពេល នោះនាំឲ្យអេសុបមានការណ៍ចូលទៅក្នុងខ្ទម ។ បានលេសបន្តិចប៉ុណ្ណឹង អាគាថូពុះ បបួលគ្នាក៏ស៊ីផ្លែក្រខុបអស់ ហើយទំលាក់ទោសទៅលើអេសុប ព្រោះស្មានថាលោករកខុសត្រូវពុំឃើញ ព្រោះលោកនិយាយដាប់ៗ ហើយដូចជាក្អឹកក្អឺតផង ។ មនុស្សសម័យពីដើមធ្វើទោសខ្ញុំកំដរអាក្រក់ណាស់ ហើយក្នុងរឿងនេះ អេសុបប្រាកដជាត្រូវមានជាប់ពិរុទ្ធ យ៉ាងធ្ងន់ ។

អេសុបលុតជង្គង់សំពះចៅហ្វាយនាយ ហើយខំនិយាយធ្វើដៃជាសញ្ញាឲ្យយល់ថា លោកសូមពរឲ្យគេត្បួរទោសមួយស្របក់សិន ។ លោកកុដុម្ពិក៍ស្ដាប់បានយល់ព្រមតាម, អេសុបរត់ទៅរកទឹកក្ដៅអ៊ុនៗយកមកផឹក នៅចំពោះមុខចៅហ្វាយនាយ ហើយយកម្រាមដៃលូកក្នុងបំពង់កឲ្យក្អួត គេឃើញសុទ្ធតែទឹកដដែលចេញមកវិញ, គ្មានឃើញផ្លែក្រខុបសោះ ។ រួចហើយ អេសុបធ្វើសញ្ញាឲ្យម្ចាស់របស់លោកបង្គាប់អាប៉ុន្មានអ្នកឲ្យធ្វើដូចលោក ។ អ្នកពលគ្នាសង្ស័យហើយគិតថា បំណោះហ្នឹងមិនមែនជាបំណោះដោះខ្លួនរួចទេ ។ ពួកអាប៉ុន្មាននាក់ដូចជាគ្មានភ័យសោះ ក៏នាំគ្នាផឹកទឹកក្ដៅហើយធ្វើដូចអេសុប ស្រាប់តែខ្អួតមកសុទ្ធតែផ្លែក្រខុបនៅស្រស់ញញឹម ។ ពួកអាគាថូពុះត្រូវមានទោសជាទ្វេគុណ ៙ ទី ៗ

ដោយលួចស៊ីផ្លែក្រូច, ទី ២ ដោយចិត្តអាក្រក់បង្វែរទោសដាក់លើគេ, ចំណែកអេសុបរួចទោស ។

ព្រឹកឡើងលោកកុដុម្ពិក៏ត្រឡប់ទៅផ្ទះវិញ, អេសុបនៅធ្វើការតាមធម្មតា ។ មានអ្នកដំណើរ ៣-៤ នាក់វង្វេងផ្លូវ ហើយមកអង្វរឲ្យអេសុបអាណិតបង្ហាញផ្លូវដែលទៅកាន់ទីក្រុងធំ ។ អេសុបឃើញដូច្នោះ ក៏ឲ្យអ្នកដំណើរនោះសម្រាកនៅក្រោមម្លប់ឈើសិន ទៅរកទឹកយកមកឲ្យផឹកដើម្បីឲ្យបាត់ស្រេក, លុះកិច្ចនេះរួចហើយ ទើបលោកនាំអ្នកវង្វេងផ្លូវទៅដាក់នៅផ្លូវធំជាស្រេចបានលោកត្រឡប់មកវិញ ។ អ្នកដំណើរមុននឹងចៀសចេញទៅ លើកដៃទៅលើតាំងសច្ចាថា "សូមទេវតាទាំងឡាយនៅទីនេះកុំមើលបំណាំ ទុកសេចក្ដីល្អនៃឈ្មោះនេះឲ្យនៅឥតផល" ។

អេសុបគ្រាន់តែចេញផុតពីអ្នកដំណើរបានបន្តិច ក៏ចូលទៅដេកក្រោមម្លប់ឈើមួយដើម ព្រោះថ្ងៃក្ដៅពេក ហើយអស់កំឡាំងផង ។ កំពុងដេកលក់ លោកយល់សប្ដិឃើញដូចមានបុរសម្នាក់ មកលាអណ្ដាតរបស់លោកឲ្យនិយាយរួចដូចមនុស្សផងទាំងពួង លោកកំពុងតែសប្បាយចិត្ត លោះភ្ញាក់ឡើងហើយនឹកក្នុងចិត្តថា "យី ឥឡូវសំដីរបស់អញ គ្មានជាប់ទេតើ! អញហៅនាសក៏ច្បាស់ នង្គ័លក៏ច្បាស់តាមចិត្តចង់" ។ ការណ៍អស្ចារ្យនេះ នាំឲ្យអេសុបផ្លាស់នាយហៅហ្វាយថ្មីទៀត ព្រោះមេតំរួតនៅធ្វើចំការខ្វាចខ្ទួនក្រុងវៀងដែលរាំបានធ្វើបាបគេនោះ នឹងដឹង

ផល់ចៅហ្វាយនាយ ដ្បិតវាជាអ្នកត្រួតលើកូនឈ្នួល មើលការណ៍ខុសត្រូវ ហើយជាអ្នកសឲ្យទោសផង ។ ពីថ្ងៃមុនវាបានធ្វើបាបកូនឈ្នួលម្នាក់មិនត្រូវតាមច្បាប់ កំហុសនេះវាស្មានថា អេសុបពុំនៅស្ងៀម មុខជាយកទៅប្រាប់លោកគុដម្ពីគ៍ជាមិនខាន ។ ដើម្បីនឹងបំបាត់រឿងទុច្ចរិត ហើយនឹងការសងសឹកខ្លួនវា ទៅដំកបលោកគុដម្ពីគ៍ថា "ឥឡូវនេះមានហេតុប្លែកកើតឡើងក្នុងផ្ទះលោក គឺថាអេសុបចេះស្តី ចេះនិយាយហើយៗ មុខជានិយាយដើមពីលោកជាមិនខាន" ។ លោកគុដម្ពីគ៍ ឮដូច្នោះហើយ ជឿនិយាយថា: "ចូរឯងប្រាប់ថា: បើវាចង់ទៅណាក៏ទៅចុះ យើងលែងទុកវាឲ្យនៅហើយ" ។ មេនាយគំរូត្រឡប់មកវិញ ប្រទះឈ្នួញម្នាក់ស្វែរកទិញសត្វលាដើម្បីផ្ទុកអីវ៉ាន់ ។ វាឆ្លើយថា "ខ្ញុំគ្មានទេសត្វលា បើអ្នកចង់ទិញមនុស្ស ទើបខ្ញុំមាន" ។ ថាដូច្នោះហើយ វានាំអេសុបយកមកឲ្យមើល ។ ឈ្នួញស្តីថា "អ្នកកុំលេងចំអកឲ្យខ្ញុំដូច្នេះ មនុស្សដូចជាការុងអ្នកហានយកមកលក់ឲ្យខ្ញុំ" ។ រួចហើយឈ្នួញក៏ដើរចេញទៅនិយាយផងសើចផង អំពីរូបរាងអេសុប ។ អេសុបស្រែកហៅឈ្នួញមកវិញ ហើយប្រាប់ថា "សូមលោកទិញខ្ញុំយកទៅចុះ មិនឥតប្រយោជន៍ទេ បើលោកមានកូនចៅវាយំច្រើនឬវាកាច មុខខ្ញុំគ្រាន់បានយកទៅពន្យួយបន្លាចវាឲ្យនៅស្ងៀម" ។ ពាក្យដែលអេសុបនិយាយហាក់ដូចជាត្រូវចំណុចចិត្តរបស់ឈ្នួញៗ ក៏ព្រមទិញលោកយក ថ្លៃជាប្រាក់បីអូបុល (obole)

គិតជាប្រាក់យើងប្រហែល ៣ សេន ហើយនិយាយសើចថា "អញទិញមនុស្សនេះដូចជាបោះប្រាក់ចោលទទេ" ។

ឯឈ្មួញនេះមិនជួញត្រឹមតែរបស់ទេ ជួញទាំងមនុស្សផង កាលណាទៅដល់ក្រុង ១ ឈ្មោះ អេភេសូស (Ephèse) គាត់នឹងលក់របស់ព្រមទាំងមនុស្សចេញខ្លះ ។ វេលារៀបធ្វើដំណើរទៅ គេឲ្យមនុស្សទាំងឡាយយកវត្ថុផ្សេងៗ រៀងខ្លួនតាមកំឡាំង ។ អេសុបអង្វរមនុស្សទាំងនោះឲ្យអាណិតលោកផង កុំឲ្យលោកយករបស់ធ្ងន់ៗពេក ដ្បិតខ្លួនរបស់លោកវិកលវិការៈ ។ មនុស្សទាំងឡាយឆ្លើយថា "តាមតែឯងចុះ ចង់យកក៏បាន ដើរខ្លួនទទេក៏បាន គ្មាននរណាប្រណែនឡើយ" ។ អេសុបបានចិត្តចង់យកដូចគេដែរ: មនុស្សទាំងអស់ថា: "បើដូច្នោះ ចូរឯងរើសមើលចុះ របស់ណាស្រាល យកអាហ្នឹងចុះ" ។ លោករើសយកកញ្ជើអាហារដែលធ្ងន់ជាងគេ, ពួកមនុស្សឯទៀតគិតគ្នាថា "អានេះចំជាល្ងើ" ហើយក៏នាំគ្នាដើរចេញទៅ ។ ដល់ពេលបាយ គេបរិភោគអាហាររៀងខ្លួន មិនយូរប៉ុន្មានបានតែពីរពេលបាយអស់រលីងពីកញ្ជើ លោកដើរតែខ្លួនទទេ ទើបអ្នកទាំងអស់គ្នាគ្នាក់ខ្លួននាំគ្នាសរសើរប្រាជ្ញារបស់អេសុប ។

ចំណែកឈ្មួញ លក់អីវ៉ាន់នឹងមនុស្សទាំងអស់ ទុកតែគ្នា ៣ នាក់គឺ: អ្នកចេះខាងវេយ្យាករណ៍ ១, អ្នកចំរៀង ១, អេសុប ១, សម្រាប់យកទៅលក់ឯក្រុងសាមូស (Samos) ។ មុននឹងនាំទៅលក់ គេឲ្យបុរសពីរនាក់

ស្លៀកពាក់យ៉ាងល្អ, ចំណែកអេសុបគេឲ្យស្លៀកបារ ហើយឲ្យឈរនៅកណ្ដាលបុរសពីរនាក់ ដើម្បីឲ្យអ្នកទាំងពីររឹងរឹតតែល្អឡើង គេនឹងលក់បានតម្លៃច្រើន ។ មានអ្នកប្រាជ្ញខាងទស្សនវិជ្ជាម្នាក់ឈ្មោះសង្ទុះ (Xanthus) មកតថ្លៃបុរសចេះវេយ្យាករណ៍នឹងអ្នកចំរៀង ហើយសួរថា: «ឯងចេះអ្វីខ្លះ?» ។ បុរសទាំងពីរនាក់ឆ្លើយថា «យើងចេះធ្វើសព្វទាំងអស់» ។ អេសុបឮដូច្នោះអស់សំណើចតែម្នាក់ឯង ។ មុខលោកតែសើចឡើងកាលណា បើមនុស្សធ្លាប់ខ្លាចខ្មោច ឃើញហើយចង់រត់មិនហ៊ានមើល ព្រោះវាអាក្រក់ក្រៃពេក ។ សង្ទុះសួរទិញ, ឈ្មួញកាត់ថ្លៃពេក ។ ឈ្មួញនិយាយថា «បើអ្នកទិញបុរសណាមួយ ខ្ញុំនឹងថែមអេសុបឲ្យទទេដូចជាខ្លាច» ។ សង្ទុះមិនហ៊ានថ្លៃ ។ តែដើម្បីកុំឲ្យទៅវិញទទេ ពួកកូនសិស្សប្រាប់គ្រូឲ្យសួរទិញនូវអាកំទេចមនុស្ស ដែលសើចអម្បាញ់មិញយកទៅលេង ។ អានេះគ្រាន់ជាទីកែអផ្សុករបស់យើងដោយសារមុខរបស់វា ។ គ្រូរបស់វាយល់ព្រមក៏សួរថា «ឯងចេះធ្វើអ្វីខ្លះ?» ។ អេសុបឆ្លើយថា «ខ្ញុំគ្មានចេះអ្វីទេ ព្រោះគេពីរនាក់នេះចេះធ្វើអស់រលីងទៅហើយតើខ្ញុំបានអ្វីនឹងធ្វើ!» ។ សង្ទុះត្រូវចិត្តហើយទិញលោកយកតម្លៃជាប្រាក់ ៥០ អូបុល ។

(មានត)

# ប្រវត្តិព្រះកែវមរកត

## អ្នកឧកញ៉ា ទេពពិទូរ ក្រសេម គន្ធបណ្ឌិត

រៀបរៀង

### សេចក្តីផ្តើម

រឿងប្រវត្តិព្រះកែវមរកត ទោះបីយ៉ាងណាក៏ដោយ ខ្ញុំបានស្តាប់សេចក្តីគេនិយាយដំណាល និងបានមើលរឿងរ៉ាវដែលគេតែងទុក ទាំងជាភាសាខ្មែរ ទាំងជាភាសាសៀម ស្ទើរតែគ្មានសល់រឿងណាមួយ ៗ តែក្នុងរឿងទាំងអំបាលនោះ មានរឿងខ្លះ ដែលខ្ញុំមិនសូវជិតចិត្តជឿតាម ព្រោះមានពិរុទ្ធនៅក្នុងខ្លួន តួយ៉ាងដូចរឿងដែលដំណាលថា កាលទ័ពសៀមលើកមកឡោមព័ទ្ធបន្ទាយលង្វែកប្រមាណក្នុងឆ្នាំ ព.ស. ២១៣៦ ដើម្បីប្លន់យកព្រះកែវមរកត ខ្មែរបានយកព្រះកែវមរកត ទៅលាក់ទុកនៅគុម្ពឫស្សី ដើម្បីកុំឲ្យសៀមចូលយកបាន ។ល។ នោះជារឿងមិនពិត ព្រោះព្រះកែវមរកតមិនដែលមកស្ថិតនៅបន្ទាយលង្វែកទេ ។ ដូច្នេះជាហេតុឲ្យខ្ញុំទាក់ចិត្ត ទើបស្រាវជ្រាវរកសេចក្តីពិតរបស់រឿងនេះតមក តែមិនមានឱកាសនឹងបំពេញកិច្ចនេះ ដោយពេញលេញ ។

លុះមកដល់សម័យ ១ ដែលខ្ញុំទទួលភារៈស្រាវជ្រាវនឹងរៀបរៀងរឿងព្រះរាជពង្សាវតារ ក៏បានស្រាវជ្រាវទាំងរឿងព្រះកែវមរកតជាមួយគ្នាផង ព្រោះរឿងនេះ ទាក់ទងដោយរឿងប្រវត្តិសាស្ត្រដែរ ។ ការរៀបរៀង

ប្រវត្តិព្រះកែវមរកតគ្រានេះ សុំឲ្យជ្រាបថា ដោយអាស្រ័យតាមគោលប្រវត្តិសាស្ត្រដែលខ្ញុំស្រាវជ្រាវក្នុងបច្ចុប្បន្ន និងតាមរឿងប្រវត្តិព្រះកែវមរកត ដែលគេតែងជាភាសាសៀមបោះពុម្ពក្នុងឆ្នាំ ព.ស. ២៤៧២ ។

រឿងនេះ ទោះបីជាដូចម្ដេចក៏ដោយ ខ្ញុំមានសេចក្ដីសង្ឃឹមថា គង់ចូលក្នុងលក្ខណៈត្រឹមត្រូវគ្រាន់បើ តែនៅមានសេចក្ដីបារម្ភថា ប្រហែលជានៅមានភ្លាត់ខុសឆ្គងខ្លះមិនខាន ទើបសូមឧកាសបវារណាទុកជាមុនថា បើអស់លោកអ្នកណាបានមើលហើយឃើញខុសឆ្គងត្រង់កន្លែងណា សូមមេត្តាជួយផ្ដល់ឬជួយតម្រង់ឲ្យបានផង ។

---

## ព្រះកែវមរកត

## វយៈ ទី ១

### កំណើតព្រះកែវមរកតនៅឥណ្ឌា

ក្នុងរវាង ព.ស. ៥០០ - ១.០០០

ព្រះកែវមរកត (ក្នុងវេលានេះនៅក្រុងបាងកក) កើតឡើងប្រមាណជាក្នុង ព.ស. ៥០០. ដំបូងឡើង ព្រះនាគសេនត្ថេរដ៏ជាព្រះអរហន្ត នៅអសោការាម ក្រុងបាតលិបុត្រ ប្រទេសមគធៈ មានប្រាថ្នានឹងសាងព្រះពុទ្ធបដិមាករ ជាតំណាងអង្គព្រះសម្មាសម្ពុទ្ធដែលបរិនិព្វានទៅហើយ ។

សេចក្ដីនោះ បានជ្រាបទៅដល់ព្រះឥន្ទ្រ ក៏ទ្រង់ជ្រះថ្លាក្នុងការសាង នេះដែរ ទើបត្រាស់ប្រើវិស្សុកម្មទេវបុត្រឲ្យទៅសុំកែវមរកតអំពីប្រមុខយក្សដែលនៅរក្សាកែវឆ្មេរ៍ ទៅក្នុងវិបុល ។ តែប្រមុខយក្សពុំព្រមឲ្យ ដោយអាងថាទុកសម្រាប់ថ្វាយស្ដេចចក្រពត្តិ ដែលនឹងកើតក្នុងលោកនេះទៅក្នុងអនាគត ។ វិស្សុកម្មត្រឡប់ទៅទូលព្រះឥន្ទ្រវិញតាមដំណើរ ។ ព្រះឥន្ទ្រព្រមដោយវិស្សុកម្ម ក៏ស្ដេចទៅរកប្រមុខយក្ស ទ្រង់ថ្លែងអំពីប្រយោជន៍ដែលសាងព្រះពុទ្ធរូបសព្វគ្រប់ហើយ ក៏ត្រាស់សុំយកកែវមរកត ។ ប្រមុខយក្សក៏ព្រមថ្វាយកែវមរកតមួយដុំធំ ។ ព្រះឥន្ទ្រឲ្យវិស្សុកម្មនាំយកកែវនោះទៅប្រគេនព្រះនាគសេន ឲ្យសាងព្រះពុទ្ធរូប ទាំងត្រាស់ឲ្យវិស្សុកម្មនៅជួយសាងផង ។ ដោយហេតុវិស្សុកម្មធ្លាប់បានឃើញព្រះពុទ្ធអង្គក្នុងកាលគង់ព្រះជន្មនៅ អាចនឹងសាងព្រះពុទ្ធរូបឲ្យមានលក្ខណៈប្រហែលនឹងព្រះអង្គដោយច្រើន ។ កាលសាងស្រេចហើយ ព្រះនាគសេនបានបញ្ចុះព្រះបរមធាតុ ៧ អង្គ នៅក្នុងព្រះកែវមរកតនោះ គឺនៅព្រះសិរ ១ អង្គ, នៅព្រះនលាដ ១ អង្គ, នៅព្រះឧរ ១ អង្គ, ព្រះអង្សា (ស្មា) ស្ដាំ ១ អង្គ, ព្រះអង្សាឆ្វេង ១ អង្គ, ព្រះជង្ឃ (ជង្គង់) ស្ដាំ ១ អង្គ, ព្រះជង្ឃឆ្វេង ១ អង្គ ។

ខ្នាតព្រះកែវមរកតនោះ តាមដែលគេវាស់ក្នុងកាលឥឡូវនេះ-ដូច្នេះ

កំពស់ព្រះអង្គ ១ ហត្ថ ៧ ធ្នាប់

ព្រះភ្នែន ២៣ ធ្នាប់ ។

ក្រោយដែលសាងហើយ គេបានសាងមណ្ឌបប្រតិស្ឋានព្រះកែវមរកត នោះនៅក្រុងបាតលិបុត្រ ហើយមានការធ្វើពិធីសម្ភោធផ្ចង់ជាខ្លាំងក មានមហាជនអំពីគ្រប់ទិសមកមើលច្រើនមហិមា ដោយគេសំគាល់ថាជារបស់វិសេសអស្ចារ្យ ជាទស្សនានុត្តរិយវត្ថុ ទើបទើងកើតមានឡើង ។

ដោយហេតុព្រះកែវមរកតជាវត្ថុវិសេសអស្ចារ្យនោះ ព្រះនាគសេនទើបទាយពាក្យករណ៍ទុកថា "ព្រះកែវមរកតអង្គនេះ ទៅក្នុងអនាគតនឹងស្ថិតនៅបានតែក្នុងប្រទេស ដែលកាន់ព្រះពុទ្ធសាសនា ហើយជាប្រទេសថ្កើងរុងរឿង" ។

## វយ: ទី ២

## ព្រះកែវមរកតចេញចាកឥណ្ឌាទៅស្ថិតនៅលង្កាទ្វីប

## ពី ព.ស. ១.០០០ - ១.៦០០

សេចក្តីព្យាករណ៍របស់ព្រះនាគសេននោះមិនបានឃ្លៀងឃ្លាតឡើយ ដោយហេតុក្រោយនោះ ប្រទេសមគធៈកើតបះបោរចលាចលកាប់សម្លាប់គ្នាដើម្បីដណ្តើមរាជបល្ល័ង្ក, ក្នុងពេលនោះ ការព្រះសាសនាក៏ទ្រុឌទ្រោមថយចុះយ៉ាងច្រើន ។ ក្នុងទីបំផុត មកក្នុងរជ្ជកាលព្រះបាទសិរីកិត្តិរាជក្នុងរាជ្យ ព.ស. ១.០០០ ជាសម័យដែលបណ្តាលកើតក្តៅក្រហាយខ្លាំងឡើង ទើបមានពុទ្ធបរិស័ទ ១ ពួកបានអញ្ជើញព្រះកែវមរកតចុះកាន់សំពៅបើកមកតាមទន្លេគង្គាចេញទៅដល់ពាមទន្លេបេង្គ័ល ហើយបើក

សំពៅឆ្ពោះទៅកោះលង្កា ដោយបំណងបណ្ដោះយកព្រះកែវមរកតទៅប្រតិស្ឋានទុកនៅទីនោះ ឲ្យរួចអំពីកណ្ដាប់ដៃពួកមិច្ឆាទិដ្ឋិបំផ្លាញ ។ ព្រោះក្នុងពេលនោះ ព្រះពុទ្ធសាសនានៅកោះលង្កាកំពុងចំរើនជាងនានាប្រទេសទាំងអស់ ។

កាលព្រះកែវមរកតអណ្ដែតត្រសែតទៅដល់កោះលង្កាហើយ ពួកពុទ្ធមាមកៈនៅលង្កា មានព្រះមហាសង្ឃបរិនាយក និងព្រះមហាក្សត្រិយ៍ជាអាទិ៍ ក៏ត្រេកអរទទួលនិមន្តទៅប្រតិស្ឋានទុកនៅវត្តមេឃគីរីមហាវិហារ ដែលជាវត្តសំខាន់ក្នុងក្រុងនោះ ។ អំពីនោះព្រះពុទ្ធសាសនានៅលង្កាក៏សន្សឹមចំរើនរុងរឿងមកអស់កាលដ៏យូរ ។

តែសម័យតមក ប្រទេសលង្កាត្រូវទទួលគ្រោះថ្នាក់ជាច្រើនលើក ដោយត្រូវទមិឡដែលនៅក្នុងដែនឥណ្ឌា លើកទ័ពចូលទៅវាយបែកខ្ទេចខ្ទី រហូតដល់ទៅបានឡើងគ្រងរាជបល្ល័ង្កជាច្រើនដង ។ ព្រះពុទ្ធសាសនាក្នុងគ្រានោះធ្លាក់រៀវរោយជាច្រើន ដោយស្នាដៃពួកមិច្ឆាទិដ្ឋិនេះបៀតបៀន ។ តែក្រោយមក ក្សត្រិយ៍លង្កាបានរើខ្លួនពីកណ្ដាប់ដៃទមិឡឡើងវិញក៏ផ្ដើមទំនុកបម្រុងព្រះពុទ្ធសាសនាឲ្យរុងរឿងយ៉ាងដើម, ដូចជាក្នុងសម័យពុទ្ធសតវត្សរ៍ទី ១៦ ក្នុងរជ្ជកាលក្សត្រិយ៍ព្រះនាមហៅតាមក្នុងសង្គីតិវង្សថា "លក្ខិស្សរាជ" ទ្រង់បានបាត់បែងទំនុកបំរុងព្រះពុទ្ធ-សាសនាជាថ្មីទៀត តែក៏មិនបានជាចំរើនប៉ុន្មាន ។ ចំណែកឯគម្ពីរព្រះ

ត្រៃបិដកនៅមានគ្រប់បរិបូណ៌ ទាំងបែបភាសាបាលីទាំងបែបភាសាលង្កា ។

ព្រះកែវមរកតទៅស្ថិតនៅកោះលង្កា ដោយអាការយ៉ាងនេះ ។

## វគ្គៈ ទី ៣

### ព្រះកែវមរកត ចេញចាកលង្កាមកប្រតិស្ឋាន នៅក្រុងស្រីយសោធរបុរៈប្រទេសកម្ពុជា

### ពីរវាង ព. ស. ១ ៥៦០ - ១ ៦៤៣

ហេតុដែលព្រះកែវមរកតមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជា ប្រាកដតាមប្រវត្តិសាស្ត្រថាៈ ក្នុងរវាង ព ស. ១ ៥៥៣ ដល់ ១.៥៩៥ ប្រទេសកម្ពុមានព្រះមហាក្សត្រិយ៍ ១ អង្គព្រះនាមអនិរុទ្ធឬអនុរុទ្ធ មានព្រះកិត្តិយសជាមហាកជ ទ្រង់ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងខ្លាំង បានផ្តើមទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងប្រទេសឲ្យចំរើនឡើង ។ តែក្នុងវេលានោះ ព្រះត្រៃបិដកក្នុងប្រទេសកម្ពុមានមិនគ្រប់បរិបូណ៌, ទ្រង់ជ្រាបថា នៅលង្កាមានចប់បរិបូណ៌ ទើបស្តេចឲ្យគាក់តែងសំពៅពីរ ហើយស្តេចចុះសំពៅទៅលង្កាទ្វីបជាមួយនឹងអ្នកប្រាជ្ញជាច្រើន មានទាំងគ្រហស្ថទាំងបព្វជិត ដើម្បីចំឡងព្រះត្រៃបិដក ។

## ប្រវត្តិព្រះអនុរុទ្ធត្ថេរ

## ហ្លួងពិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

ព្រះអនុរុទ្ធត្ថេរនេះ ជាបុត្ររបស់ព្រះអមិតោទនសក្យរាជ ដែលជាព្រះអនុជព្រះបាទសុទ្ធោទនសក្យរាជគ្រងក្រុងកបិលពស្តុ ប្រសូតចេញពីព្រះមាតារួមជាមួយគ្នា ៣ អង្គ គឺៈ ព្រះជេដ្ឋាព្រះនាមមហានាមសក្យ ១ ព្រះកនិដ្ឋភគិនី (ប្អូនស្រី) ព្រះនាមរោហិនី ១ ជា ៣ អង្គទាំងព្រះអនុរុទ្ធកុមារ បើរាប់រៀងតាមព្រះវង្សត្រូវជាព្រះអនុជព្រះបរមសាស្តា ។ ព្រះអនុរុទ្ធកុមារនេះជាក្សត្រសុខុមាលជាតិ មានប្រាសាទ ៣ សម្រាប់នៅក្នុងរដូវទាំង ៣ បរិបូណ៌ដោយស្រីស្នំស្រីង្គារបរិវារទាំងពួង សូម្បីសព្វតែពាក្យថាមិនមានឬគ្មាន ក៏មិនដែលឮមិនដែលស្តាប់ឡើយ ។ សម័យ ១ ព្រះបរមសាស្តា ស្តេចប្រថាប់នៅអនុបិយនិគមរបស់ពួកមល្លក្សត្រ, ក្នុងវេលានោះ ពួកសក្យកុមារដែលមានកេរ្តិ៍ឈ្មោះមានមនុស្សស្គាល់ច្រើន នាំគ្នាចេញទៅបួសតាមសម្តេចព្រះបរមសាស្តា ។ ថ្ងៃ ១ ព្រះមហានាមដែលជាព្រះជេដ្ឋាប្រារព្ធដល់រឿងនេះហើយ ទើបទៅពិគ្រោះប្រឹក្សានឹងព្រះអនុរុទ្ធជាប្អូនថា " ម្នាលអនុរុទ្ធ ! ក្នុងត្រកូលរបស់យើងមិនមានអ្នកណាមួយ ចេញទៅបួសតាមព្រះបរមសាស្តាឡើយ បើដូច្នោះ មានតែប្អូនឬខ្ញុំបងចេញទៅបួសតាមព្រះអង្គទើបសមគួរ " ។ ព្រះអនុរុទ្ធ

ឆ្លើយឡើងថា "ប្អូនជាមនុស្សធ្លាប់តែនៅក្នុងសេចក្ដីសុខ ប្អូនមិនព្រមទៅបួសទេ អញ្ជើញស្ដេចបងទៅបួសចុះ" ។ ព្រះមហានាមពោលឡើងថា "បើដូច្នេះ ត្រូវប្អូនរៀនសូត្រឲ្យចេះដឹងការងាររបស់អ្នកនៅគ្រប់គ្រងផ្ទះសិនបងនឹងបង្រៀនឲ្យចេះដឹង" លុះពោលដូច្នេះ ទើបបង្រៀនអនុរុទ្ធអំពីការងាររបស់អ្នកនៅគ្រប់គ្រងផ្ទះ លើកយកការធ្វើស្រែជាដើមឡើងអធិប្បាយពន្យល់សព្វគ្រប់ ។ កាលព្រះអនុរុទ្ធបានស្ដាប់ហើយក៏ឃើញថា "ការងារនេះមិនមានទីបំផុត ទីបំផុតរបស់ការងារមិនមាន" ទើបកើតចិត្តនឿយណាយក្នុងការងារ រួចពោលទៅនឹងស្ដេចបងថា "បើដូច្នោះបងនៅគ្រប់គ្រងផ្ទះចុះ ប្អូននឹងចេញទៅបួសវិញ" ។ កាលព្រះអនុរុទ្ធពោលដូច្នេះហើយ ទើបចូលទៅគាល់ព្រះមាតាទូលថា "ព្រះម្ចាស់! ខ្ញុំម្ចាស់ចង់ទៅបួស សូមព្រះម្ចាស់អនុញ្ញាតឲ្យខ្ញុំម្ចាស់ទៅបួសចុះ" ។ ឯព្រះមាតាត្រាស់ហាមមិនព្រមឲ្យចេញទៅបួស, ព្រះអនុរុទ្ធក៏ចេះតែទទូចទូលអង្វរសូមអនុញ្ញាតជាច្រើនគ្រា ។ ព្រះមាតាឃើញដូច្នោះទើបគិតរកឧបាយមិនឲ្យព្រះអនុរុទ្ធចេញបួស ដោយរលឹកនឹកឃើញដល់ព្រះបាទភទ្ទិយៈជាសំឡាញ់របស់ព្រះអនុរុទ្ធ ថាមុខជាទ្រង់មិនព្រមទៅបួសជាប្រាកដ ទើបមានព្រះបន្ទូលថា "បើព្រះបាទភទ្ទិយៈទ្រង់ព្រះផ្នួស ចូរកូនបួសចុះ" ។ កាលព្រះអនុរុទ្ធបានស្ដាប់ព្រះមាតាដូច្នេះហើយ ទើបចូលទៅគាល់ព្រះបាទភទ្ទិយៈ ទូលតាមវោហារដែលធ្លាប់ស្និទ្ធស្នាលថា

" សំឡាញ់អើយ ! គន្លងបញ្ញារបស់យើងជាប់ទាក់ទងនឹងបញ្ញារបស់សំឡាញ់" ។ ដំបូងព្រះបាទភទ្ទិយៈ ទ្រង់បដិសេធមិនព្រមទ្រង់ព្រះផ្នួសតែត្រានឹងពាក្យអនុរុទ្ធមិនបានក៏ដាច់ព្រះហឫទ័យព្រមទទួលបួសផង ៗ ទើបព្រះអនុរុទ្ធទៅបបួលសក្យរាជដទៃទៀត ៣ អង្គ គឺ អានន្ទ ១ ភគុ ១ កិម្ពិល ១ កោលិយវង្ស គឺទេវទត្ត ១ ត្រូវជា ៧ នាក់ នឹងឧបាលិដែលជាខ្ញុំព្រះកេស ព្រមចិត្តគ្នាចេញអំពីស្រុកទៅគាល់ព្រះបរមសាស្ដាឯអនុបិយនិគម ហើយក្រាបទូលសុំឧបសម្បទ ក្នុងព្រះពុទ្ធសាសនា ៗ កាលព្រះអនុរុទ្ធបានឧបសម្បទហើយ បានរៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្តត្ថេរ ហើយបានចូលទៅចំរើនសមណធម៌នៅព្រៃបាចិនវង្ស-មិគទាយវន បានត្រិះរិះដល់ព្រះមហាបុរិសវិតក្កៈ ៧ ប្រការថាៈ

១ – ធម៌នេះជាធម៌របស់អ្នកប្រាថ្នាតិច មិនមែនរបស់អ្នកប្រាថ្នាធំឡើយ ៗ

២ – ធម៌នេះជាធម៌របស់អ្នកសន្ដោសត្រេកអរដោយរបស់ដែលមាននៅ មិនមែនរបស់អ្នកមិនសន្ដោសឡើយ ៗ

៣ – ធម៌នេះជាធម៌របស់អ្នកស្ងាត់ មិនមែនរបស់អ្នកត្រេកអរដោយពួកគណៈឡើយ ៗ

៤ – ធម៌នេះជាធម៌របស់អ្នកប្រារព្ធសេចក្ដីព្យាយាម មិនមែនរបស់អ្នកខ្ជិលច្រអូសឡើយ ៗ

៥ – ធម៌នេះជាធម៌របស់អ្នកមានសតិខ្ជាប់ខ្ជួន មិនមែនរបស់អ្នកមានសតិវង្វេងឡើយ ។

៦ – ធម៌នេះជាធម៌របស់អ្នកមានចិត្តខ្ជាប់ខ្ជួន មិនមែនរបស់អ្នកមានចិត្តមិនខ្ជាប់ខ្ជួនឡើយ ។

៧ – ធម៌នេះជាធម៌របស់អ្នកមានប្រាជ្ញា មិនមែនរបស់អ្នកឥតប្រាជ្ញាឡើយ ។

កាលព្រះអនុរុទ្ធត្រេកត្រិះរិះយ៉ាងនេះ, ព្រះបរមសាស្តាទ្រង់ជ្រាបស្តេចយាងទៅដល់ហើយ ទ្រង់អនុមោទនាថា "ត្រូវហើយៗ អនុរុទ្ធ ! អ្នកបានត្រិះរិះដល់ធម៌ដែលមហាបុរសបានត្រិះរិះប្រពៃហើយ បើដូច្នេះ ចូរអ្នកត្រិះរិះដល់ធម៌ដែលមហាបុរសបានត្រិះរិះជាគំរប់ ៨ នេះថា:

៨ – ធម៌នេះជាធម៌របស់អ្នកត្រេកអរក្នុងធម៌ដែលមិនយឺតយូរ មិនមែនជារបស់អ្នកត្រេកអរក្នុងធម៌ដែលយឺតយូរឡើយ" ។

លុះព្រះអង្គទ្រង់ទូន្មានព្រះអនុរុទ្ធដោយប្រការដូច្នេះហើយ ទើបស្តេចយាងត្រឡប់ទៅទីប្រថាប់វិញ ។ ឯព្រះអនុរុទ្ធបានខំបំពេញព្យាយាមក៏បានសម្រេចព្រះអរហត្តផល. តាំងអំពីនោះមក លោកតែងសំឡឹងមើលសត្វលោកដោយទិព្វចក្ខុជានិច្ច ។ មានសេចក្តីដំណាលថា ក្រៅពីពេលឆាន់ចង្ហាន់ចេញ កាលវេលាដែលសេសសល់អំពីនេះ លោកតែងពិចារណាមើលពពួកសត្វទាំងពួងដោយទិព្វចក្ខុញាណ ហេតុនេះ

ហើយបានជាព្រះដ៏មានព្រះភាគត្រាស់សរសើរលោកថា ប្រសើរលើសលែងជាងភិក្ខុទាំងឡាយ ដែលមានទិព្វចក្ខុញ្ញាណ ។ ព្រះអនុរុទ្ធត្ថេរលោកបានបំពេញកិច្ចក្នុងព្រះពុទ្ធសាសនា តាមសមគួរនឹងកាលវេលា ហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វាន ក្រោយព្រះបរិនិព្វាននៃព្រះដ៏មានព្រះភាគជាម្ចាស់ ។

ចប់ ប្រវត្តិសង្ខេប របស់ព្រះអនុរុទ្ធត្ថេរ តែប៉ុណ្ណោះ ។

## សុភាសិត

ប្រាំបួនទាល់ ដប់ទាល់ កុំទាល់គំនិត
ប្រាំបួនគិត ដប់គិត កុំគិតមេឃដី
ប្រាំបួនធ្វើ ដប់ធ្វើ កុំធ្វើការអប្រិយ
ប្រាំបួនស៊ី ដប់ស៊ី កុំស៊ីអសុរោះ ។

ប៊ួរ - អ៊ិន

# រឿងនាងបងាចារ

## សាមណេរ គក - គីឡេង វត្តឧណ្ណាលោម ភ្នំពេញ

### ប្រែរៀបរៀង ជាកាព្យពាក្យ ៧

យុនសុវត្ថិ៍វេទី យូរ អ៊ុន ពិនិត្យកែ

---

ខ្ញុំសូមតែងរឿងបងាចារ ជាកាព្យពេហារដោយបរិយាយ
ទុកសម្រាប់ពួកពុទ្ធនិកាយ មើលស្ដាប់ឲ្យក្លាយឃ្លាតទីវរណា ។
និទានថាមានកូនសេដ្ឋី ជាស្រីរូបល្អសាច់ស្រស់ថ្លា
កាយុដប់ប្រាំមួយវស្សា បិតាមានទ្រព្យសែសិបកោដិ ។
នៅក្នុងនគរសាវត្ថី មានឈ្មោះពុល្យីគួរឲ្យកោត
ដ៏តាប្រឹមប្រិយល្បីនាមគោត្រ រូបសោភល្អផុតស្រីនានា ។
មាតាឲ្យនៅលើប្រាសាទ ប្រាំពីរជាន់ស្អាតសមសោភា
មានស្រីបំរើប្រសើរជា ឥតទុក្ខវេទនាពេលណាឡើយ ។
គ្រាមួយមានប្រុសពូជសេដ្ឋី ចូលស្ដីបិតាក៏ព្រមហើយ
បំរុងការឆាប់មិនព្រងើយ កម្មអើយទាញនាងឲ្យឃ្លាតឃ្លា ។
នាំនាងឲ្យស្រឡាញ់ខ្ញុំឯង វង្វេងភ្លេចគិតការល្អជា
យកខ្ញុំធ្វើប្ដីមិនរួញរា មាតាបិតាឥតដឹងសោះ ។
ថ្ងៃក្រោយដ៏តាគិតភ័យខ្លាំង ស្ទុងស្ទុកស្ទន់ស្ទាំងញ័រពន់ពោះ
ហើយនាងនិយាយគិតពិគ្រោះ នឹងប្ដីនាងនោះដូច្នេះថា ។

បងអើយយើងនៅនេះមិនបាន ក្រែងគេដឹងដានបែកការណា
ប្រសិនបើដឹងដល់បិតា គាត់ផ្ដាច់ជីវិតយើងមិនខាន ។
តែយើងបង្អង់នឹងបានទុក្ខ ដ្បិតម្ដាយឪពុកទាំងពីរប្រាណ
គេមកដណ្ដឹងខ្ញុំស្មោះស្មាន គាត់បានឲ្យខ្ញុំទៅគេហើយ ។
គេនឹងនាំគ្រឿងតំសុបណ្ណា មកជូនបិតាមិនយូរឡើយ
ខ្ញុំព្រួយខ្លាំងណាស់ទុក្ខឥតស្បើយ ដូច្នេះបងអើយយើងត្រូវរត់ ។
កាលនោះស្រះបិត្តទាំងពីរនាក់ រៀបគ្រឿងស្បៀងពាក់អាវសំពត់
យប់ជ្រៅភ័យដែលនាំគ្នារត់ គួរគិតកំសត់ដល់ធីតា ។
ធ្លាប់សុខបានទុក្ខមកដល់ប្រាណ ដើរទៅដោយដានឋានព្រៃកំព្រ
លេចលលចូលព្រៃទ្រូប៉ា មុខគួរអនិច្ចាពន់ពេកក្រៃ ។
ទៅដល់ស្រុកមួយឆ្ងាយល់ន្ទោច ត្រមោចឥតញាតិពឹងប្រស្រ័យ
នាំគ្នាធ្វើខ្ទមនៅក្បែរព្រៃ យកអ្នកដទៃធ្វើញាតា ។
រកស៊ីកាប់ឧសធ្វើស្រែស្រូវ លំបាកពេកកូវឥតឧបមា
ពីរនាក់ស្វាមីនឹងភរិយា កំសត់វេទនាប្រៀបពុំបាន ។
មុខគួរអាសូរកូនសេដ្ឋី ជាស្រីធ្លាប់សុខឥតរំខាន
ពេលនោះពិបាកដល់អង្គប្រាណ ទំនេរពុំបានក្នុងពេលណា ។
ធ្វើការនឿយហត់ជាប្រក្រតី បំរើស្វាមីនៃអាត្មា
កើតទុក្ខក្នុងចិត្តគិតខ្លោចផ្សា ស្រក់ទឹកនេត្រាឥតមានស្បើយ ។

លុះនាងមានគភ៌ក្នុងផ្ទៃពោះ  គឺហេតុកម្មគ្រោះមកដល់ហើយ
ព្រួយប្រាណណែនទ្រូងឥតមានស្បើយ  កើតទុក្ខពេញហើយក្នុងទុក ។
ទើបនាងបបួលប្រុសជាប្ដី  សូមឲ្យស្វាមីមានមេត្តា
អាណិតជូនប្អូនទៅមាតា  ប្រសូតបុត្រាណាប្រុសថ្លៃ ។
បើប្អូនប្រសូតក្នុងទីហ្នឹង  គ្មានញាតិណាដឹងជួយទុក្ខភ័យ
ដូច្នេះសូមអ្នកបងថ្លើមថ្លៃ  លកលៃជូនប្អូនទៅឆាប់ក៏ ។
ទើបប្រុសជាប្ដីនិយាយប្រាប់  ប្អូនអើយចាំស្លាប់បងចរចា
ថាបើបងជូនទៅកាលណា  មាតាបិតានឹងសម្លាប់ ។
ទើបនាងពន្យល់ដូច្នេះថា  សូមបងមេត្តាកុំសារស័ព្ទ
ធម្មតាបិតាមិនសម្លាប់  ធ្វើឲ្យកូនស្លាប់នោះគ្មានឡើយ ។
បើខឹងខ្លាំងណាស់កន្ទុះខែ  ឲ្យតែបាត់យូរនឹកឥតស្បើយ
ចិត្តទន់នឹងកូនមិនលែងឡើយ  បងអើយជូនប្អូនទៅឆាប់ណា៎ ។
ប្អូនមានទម្ងន់ធ្ងន់ក្នុងខ្លួន  ទុក្ខធំធ្ងន់ក្នុងកាយា
គ្មានញាតិណាមួយជួយរក្សា  មេត្តាជូនខ្ញុំទៅកុំខាន ។
ចំណែកស្វាមីស្ដីប្រកែក  ដដែកមិនហ៊ានជូនស្មោះស្មាន
ព្រោះខ្លាចអន្តកយស្លាប់ដល់ប្រាណ  ប្ដីក្រែងមិនបានសមប្រាថ្នា ។
ថ្ងៃក្រោយបុរសជាស្វាមី  ត្រាច់ទៅកាប់ឧសក្នុងព្រៃក្បា
ចំណែកនាងបងាចាក  ព្រួយក្នុងចិត្តាពុំមានស្បើយ ។

នាងផ្តាំអ្នកស្រុកពិតវាចា ឱ! លោកយាយតាបងប្អូនអើយ
ថាបើប្តីខ្ញុំមកដល់ហើយ អ្នកកុំកន្តើយសូមមេត្តា ។
ប្រាប់គាត់ថាខ្ញុំវិលទៅស្រុក ដ្បិតខ្ញុំវិតក្កទុក្ខខ្លោចផ្សា
ផ្តាំស្រេចនាងបង្ហាចាក យាត្រាដើរកាត់តាមព្រៃព្រៃ ។
មុខគួរឲ្យខ្លាចក្នុងព្រៃក្តី ស្វាសៅ្វងសត្វយំឮសន្ធៅ
នាងព្រួយខំប្រឹងកាត់ចិត្តទៅ ដើរក្នុងព្រៃព្រៅតែម្នាក់ឯង ។
និយាយពីខាងប្រុសជាប្តី វិលខ្ញុំចាកព្រៃដាច់សង្វែង
ដល់ខ្ទមគេប្រាប់យ៉ាងជាក់ស្តែង ភរិយាអ្នកឯងទៅស្រុកហើយ ។
បុរសជាប្តីស្តីខ្សឹកខ្សួល អាក់អួលក្នុងទ្រូងមិនមានស្បើយ
ស្រែកទួញរត់តាមនាងទាន់ហើយ និយាយជូនស្ពើយដូច្នេះថា ។
ហេតុអ្វីក៏ស្រីស្រស់ចំណាប់ នាងមកមិនប្រាប់ដល់រៀមក៏
ឲ្យរៀមភិតភ័យក្តុកចិន្តា សោកាហាមាត់រត់តាមប្អូន ។
វេសាកាលពេលនោះនាងឈឺពោះ គឺមោះខ្យល់បក់បន្ទិលកូន
ប្រសូតក្នុងព្រៃស្ងាត់ស្ងុងសូន្យ ស្វាសៅ្វងស័ព្ទកូនយំខ្លោចផ្សា ។
ប្រសូតរួចហើយទើបស្វាមី លួងលោមស្រីដូច្នេះថា
ប្អូនអើយបំណងនាងប្រាថ្នា ទៅស្រុកមាតាប្រសូតបុត្រ ។
ឥឡូវប្រសូតរួចស្រេចហើយ បានស្បើយពីទុក្ខធំបំផុត
លុមយើងទៅខ្ទមសូនបរិសុទ្ធ ថែរក្សាបុត្រទៅតាមកម្ម ។

ស្រីព្រមល្មមចិត្តនាំគ្នាទៅ កាន់ខ្ទមលំនៅចំប្រឹងទ្រាំ
ពិបាកទុក្ខព្រួយព្រោះកម្មនាំ ដៀមដាំក្នុងចិត្តឥតឧបមា ។
នៅយូរៗទៅមានគភ៌ទៀត បង្អៀតណែនណាន់ដោយទុក្ខា
ព្រួយប្រាណទឹកភ្នែកដោកកក្រា ខ្លោចផ្សាខ្វល់ខ្វាយកល់ខែថ្ងៃ ។
លោមឲ្យកស្តាជូនទៅស្រុក នៃម្តាយឪពុកមានគុណក្រៃ
ចំណែកកស្តាមានហឫទ័យ ទឹកភ័យមិនហ៊ានជូនទៅសោះ ។
ទើបនាងពកូនលបរត់ទៅ ប៉ុន្តែចិត្តនៅទឹកអាឡោះ
ទួញសោកកប់រៀបញ័រពង់ពោះ គួរឲ្យស្រណោះឥតឧបមា ។
ស្រែកទួញថាឱអ្នកស្វាមី ហេតុអ្វីអ្នកកាត់ក្តីមេត្តា
មិនព្រមជូនប្អូនទៅម៉ាតា ឲ្យកើតទុក្ខាព្រួយដល់ម៉្លឹង ។
ចិត្តអ្នកប្រែហែលមិនអាណិត អាសូរដល់ចិត្តប្អូនចំប្រឹង
ទ្រាំស៊ូនឹងអ្នកពិបាកម៉្លឹង ឬអ្នកមិនដឹងចិត្តប្អូនទេ ។
កម្មប្អូននាំឲ្យស្រឡាញ់ជាក់ កម្មអ្នកនាំស្ម័គ្រចិត្តស្និទ្ធស្នេហ៍
ស៊ូស្លាប់ស៊ូរស់ពីព្រោះតែ ចិត្តស្មោះប្រែខ្វែខ្វងចិន្តា ។
កូនអើយខ្លួនម្តាយម្តងនេះហើយ ឥតមានគោះត្រើយទ្រាំទុក្ខា
គឺកម្មកូនឯងនឹងមាតា គ្មានអ្នកឯណាទីពឹងប្រាណ ។
នាងដើរទាំងយប់ងងឹតសូន្យ តែម្តាយនឹងកូនក្នុងស្មះសាន
លុះដល់អធ្រាត្រទើបនាងបាន ដល់ឋានព្រៃជ្រៅនៅខ្លោចផ្សា ។

(មានត)

## ប្រវត្តិព្រាហ្មណ៍ចាស់

# លោក អ៊ុម គយ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់

### រៀបរៀង

---

សេចក្ដីដំណាលថា: ព្រាហ្មណ៍មហាសាលម្នាក់នៅក្រុងសាវត្ថី មានទ្រព្យ ៨ សែនកហាបណៈ មានកូនប្រុស ៤ នាក់ ៗ កាលកូននោះមានវ័យវឌ្ឍនាការចំរើនធំឡើង គាត់បានរៀបចំអាពាហមង្គលរួចហើយ ក៏ចែកសម្បត្តិឲ្យ ៤ សែន, ក្នុងកូនម្នាក់ៗ ត្រូវបានមួយសែនកហាបណៈ ៗ កាលចំណេរដ៏លង់មក នាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះ ធ្វើកាលកិរិយាទៅ គាត់នៅកំព្រាតែម្នាក់ឯង ៗ កូនទាំង ៤ នោះក៏ប្រឹក្សាគ្នាថា: “បើឪពុកយើងយកប្រពន្ធទៀត មុខជាមានកូនមិនខាន, ទ្រព្យ ៤ សែននឹងកើតអាករផ្សេងៗ ដែលនៅក្នុងកណ្ដាប់ដៃគាត់ៗ មុខជាចែកឲ្យតែកូនប្រពន្ធចុងទាំងអស់, បើដូច្នេះគួរតែយើងទៅនាំយកគាត់មកទំនុកបំរុង” ថាហើយក៏នាំយកបិតាមកទំនុកបំរុង ដោយកិច្ចមានគក់ប្រចាំជូនភោជ-នាហារទឹកគ្រឿងស្លៀកពាក់ជាដើមដោយគោរព ៗ ថ្ងៃមួយ កាលព្រាហ្មណ៍ក្រោកពីដេកក្នុងវេលាថ្ងៃ, ពួកកូនមកជួបជុំគ្នាហើយនិយាយអំពីទោសនៃការនៅគ្រប់គ្រងផ្ទះ ដោយឡែកៗពីគ្នា រួចនិយាយអង្វរថា: “លោកឪពុក! យើងជាកូនទាំងអស់គ្នានឹងបំរើលោកឪពុកតាមចំនួននេះ ដរាបអស់ជីវិត សូមកុំព្រួយឡើយ តែសូមលោកឪពុកចែកទ្រព្យសម្បត្តិ

ដែលទៅសល់តាំងអម្បាលម៉ានដល់យើងតាំងអស់គ្នាម្ដងទៀត" ។ ព្រាហ្មណ៍ក៏ព្រមចែកឲ្យកូន ក្នុងម្នាក់ៗបាន ១ សែនទៀត នៅសល់តែសំពត់ ១ ចង្កេះប៉ុណ្ណោះ ហើយចុះទៅនៅក្នុងផ្ទះកូនច្បងបង្អស់. កាលនៅបានពីរបីថ្ងៃ កូនប្រសាស្រីនោះកើតសេចក្ដីធុញទ្រាន់នឹងឪពុកក្មេក ក៏និយាយឌុដាន់ថា: "លោកឪពុកចែកទ្រព្យដល់កូនច្បងត្រឹមតែ ១ រយ ១ ពាន់កហាបណៈ ថាច្រើនណាស់ហើយ ឯកូនឯទៀតអាចឲ្យ ២ សែនម្នាក់ៗ, លោកឪពុកប្រហែលមិនស្គាល់ផ្លូវទៅកាន់ផ្ទះកូនទាំងនោះឬ? បានជាមិនទៅដាន់ផ្ទះគេ" ។ ព្រាហ្មណ៍ឮដូច្នោះ តូចចិត្តក៏ទៅកាន់ផ្ទះកូនឯទៀត, មិនយូរប៉ុន្មាន ត្រូវកូនប្រសាស្រីទាំងនោះបណ្ដេញចេញចាកផ្ទះតាមទំនងដូចគ្នា ។ គាត់ទ្រាំនៅមិនបានក៏ចេញទៅបួសស្លៀកសំពត់សដើរសូមទានតាមច្រកល្ហកប្រែបផ្ទះបុគ្គលដទៃ, ទៅជាស្គាំងស្គមរីងរៃព្រោះមិនបានភោជនាហារនឹងដំណេកស្រួល នឹកអាណិតករូបខ្លួនថា: "ឱ! អាត្មាអញចាស់ឡើងកាន់តែលំបាកខ្លាំងឡើង មិនសមបើកូនលះលែងអញឲ្យដើរសូមទានគេដីសោះ ពុំមិននឹកអាណិតអញដែលទំបីបាច់ថែរក្សាចិញ្ចឹមរាំងតាំងពីតូចមក មិនដែលឲ្យមានមោះមៃខ្វះស្លាន; បានឮថាព្រះសមណគោតម មានព្រះកក្តូវផង់សំដីពីរោះ ប្រសប់ក្នុងការទទួលរាក់ទាក់ បើដូច្នោះមានតែអាត្មាអញចូលទៅរកព្រះសមណគោតមចុះ" លុះគិតហើយ ក៏ទៅកាន់សំណាក់ព្រះសាស្ដាក្រាបថ្វាយបង្គំព្រះអង្គដោយ

គោរព ។ ព្រះជិនស្រីត្រាស់សួរថា: "នែព្រាហ្មណ៍! ហេតុអ្វីបានជាអ្នកមានសម្បុរៈសរីរៈនឹងសំលៀកបំពាក់សៅហ្មងដូច្នេះ" ។ - បពិត្រព្រះគោតមដ៏ចំរើន! ខ្ញុំព្រះអង្គមានកូនប្រុស ៤ នាក់ ឥឡូវនេះវាត្រូវគំនិតជាមួយនឹងប្រពន្ធបណ្ដេញខ្ញុំចោល ។ - ម្នាលព្រាហ្មណ៍! បើដូច្នោះអ្នកចូររៀនគាថានេះ ហើយសូត្រក្នុងទីប្រជុំជន ដែលមានកូនរបស់អ្នកទាំងនោះអង្គុយនៅជាមួយផងថា:

> ខ្ញុំត្រេកអរដោយកូនឯណាដែលកើតមកហើយផង ប្រាថ្នានូវសេចក្ដីចំរើនដល់កូនឯណាផង កូននោះក៏សមគំនិតជាមួយនឹងប្រពន្ធ ហើយបណ្ដេញខ្ញុំចោលដូចជាឆ្កែបណ្ដេញជ្រូក; ក៏កូនជាអសប្បុរសលាមកគ្រាន់តែហៅខ្ញុំថាឪៗ ប៉ុណ្ណោះ ប៉ុន្តែវាលះបង់ខ្ញុំដែលមានវ័យចាស់ដែលចូលមកក្នុងបច្ឆិមវ័យហើយ, (កូនខ្ញុំនោះ) ប្រៀបដូចរាក្សទឹក ដែលមកដោយរូបជាកូន, ឪពុកចាស់របស់កូនពាល តែងដើរសូមទានប្របផ្ទះអ្នកដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនកើតគេនាំចេញចាកចំណី, ឈើច្រត់របស់ខ្ញុំនេះប្រសើរ កូនដែលមិនស្ដាប់បង្គាប់មិនប្រសើរឡើយ, ដ្បិតឈើច្រត់នេះអាចការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់ទៅខាងមុខក្នុងទីងងឹតក៏បាន ស្ទង់ចុះក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់ជើងគង់ទប់ខ្លួនបានដោយអានុភាពនៃឈើច្រត់ ។

ព្រាហ្មណ៍ចាស់ក៏ព្រមរៀន លុះរៀនគាថានេះចប់ហើយ ក៏ចូលទៅកាន់កេងប្រជុំរបស់ពួកព្រាហ្មណ៍ ដែលមានកូនទាំង ៤ នាក់អង្គុយនៅជាមួយផង ហើយសូត្រគាថានេះ ។

"សេចក្តីដំណាលថា: ក្នុងជំនាន់នោះ ចរិយាវត្តរបស់អ្នកស្រុកគេបញ្ញត្តថា: បើកូនណាមួយបានទទួលមត៌កពីមាតាបិតាហើយ មិនទំនុកបំរុងថែទាំមាតាបិតាវិញទេ ត្រូវគេប្រហារជីវិតចោល" ។

គ្រាន់តែតាព្រាហ្មណ៍ សូត្រចប់គាថាភ្លាម, ពួកព្រាហ្មណ៍ទាំងនោះផ្អើលឆោឡោក្រោកឡើងរកដំបងព្រនង់ប្រុងនឹងវាយកូនតាព្រាហ្មណ៍ទាំង ៤ នោះចោល ។ កូនព្រាហ្មណ៍ភ័យខ្លាំងទើបក្រាបទៀបបាទបិតាហើយសូមខមាទោសបាននាំបិតាទៅទំនុកបំរុង; កូនម្នាក់ៗ បានឲ្យសំពត់ ១ គូ និងនិច្ចកត្តទៀត ។ តាព្រាហ្មណ៍លុះបានសេចក្តីសុខហើយ ក៏នឹកដល់គុណព្រះសាស្តាដែលបានបង្ហាញគាថា ទើបនាំយកសំពត់ ៣ គូ និងនិច្ចកត្តទៅថ្វាយព្រះដ៏មានព្រះភាគ; ព្រះអង្គទ្រង់ទទួលយកទេយ្យវត្ថុនោះដោយសេចក្តីអនុគ្រោះចំពោះព្រាហ្មណ៍ ។

ថ្ងៃក្រោយមក, ព្រះជិនស្រីស្តេចយាងមកបិណ្ឌបាតផ្ទះកូនព្រាហ្មណ៍ទាំងនោះ ទ្រង់សំដែងធម៌សរសើរបុគ្គលដែលចិញ្ចឹមមាតាបិតាដោយអនេកបរិយាយថា: "អ្នកទាំងឡាយដែលទំនុកបំរុងមាតាបិតា ជាការប្រពៃពេកណាស់ ត្រូវតាមទំនងគន្លងរបស់អ្នកប្រាជ្ញពីបុរាណមកលោកធ្លាប់ប្រព្រឹត្តសន្សំមិនដែលលះបង់ឡើយ" ទើបព្រះអង្គនិទានរឿងដូចតទៅនេះ:-

ក្នុងកាលកន្លងទៅយូរហើយ កាលនោះពោធិសត្វកើតជាដំរី ឈ្មោះធនបាលកៈ មានរោមៈសសុទ្ធ មានឥន្ទ្រិយពេញលេញ គួរពិតពិលរំមិលមើលនៃភ្នែកអ្នកផង នៅក្នុងព្រៃហិមពាន្តជាមួយនឹងមាតាចាស់ងងឹត នឹងហ្វូងដំរីដទៃទៀតជាច្រើន ។ ថ្ងៃមួយពោធិសត្វកើតសេចក្តីធុញទ្រាន់នឹងពួកបរិវារ ព្រោះមិនបានបំរើមាតាដែលខ្វាក់ងងឹតងងល់ដោយគោរព ទើបគេចខ្លួននាំយកមាតាទៅលាក់ក្នុងភ្នំចណ្ឌោរណៈ ដើរស្វែងរកផ្លែឈើមើមឈើនឹងស្មៅទុំជាដើម មកបញ្ចុកមាតារាល់ថ្ងៃ ។

ចំណេរចីរកាលតមកខាងក្រោយ, ព្រានព្រៃម្នាក់នៅក្រុងពារាណសី ដើរបរបាញ់សត្វ ដល់ត្រង់កន្លែងនោះក៏វង្វេងផ្លូវ ស្រែកយំក្តុងៗ កណ្តាលព្រៃ ។ ពោធិសត្វនឹកអាណិតអាសូរក៏ចាប់បុរសនោះឲ្យជិះលើខ្នងនាំទៅកាន់ក្រុងពារាណសីវិញ ។ រីឯបុរសនោះ ជាមនុស្សចិត្តអាក្រក់ ទ្រុស្តមិត្រ អកតញ្ញូ ។ កាលដែលដំរីមង្គលរបស់ស្តេចពារាណសីស្លាប់ទៅ ទ្រង់ឲ្យរាជបុរសប៉ាវគងខ្លួនដើរ រកដំរីដែលមានមាឌធំសក្តិសមគួរយកធ្វើជាព្រះទីនាំងបាន ។ បុរសនោះប្រាប់រាជបុរសតាមទំនងដែលខ្លួនឃើញដំរីពោធិសត្វនៅភ្នំចណ្ឌោរណៈ ក៏ធ្វើជាមគ្គុទ្ទេសក៍នាំគេទៅចាប់ពោធិសត្វមកថ្វាយ ។ ព្រះបាទពារាណសីទ្រង់ទតឃើញកាលណា មានព្រះហឫទ័យត្រេកអរសោមនស្ស ទើបត្រាស់បង្គាប់ឲ្យគេនាំទៅកាន់រោងដំរី ហើយបិទ

ប៉ាំងកំផែងនេះ ព្រោះព្រាត្រៀងក្រអូបឆ្ងៀងៗ ហើយឲ្យចំណីដែលមានរសឆ្ងាញ់ ៗ តែជនបាលកៈ មិនព្រមបរិភោគសោះ អស់ក្តៈពីរថ្ងៃ ទើបព្រះពជាទិកឆ្ងល់ត្រាស់សួរធំថា: “ព្រោះហេតុអ្វី បានជាអ្នកមិនបរិភោគចំណីនេះអ្នករញកព្រៃ ឬឈឺថ្កាត់ក្នុងខ្លួនប្រាណ?” ៗ – បពិត្រព្រះនរិន្ទពិននរបតី ! បានជាខ្ញុំមិនបរិភោគចំណីនុះ ព្រោះចង់ទៅបំរើមាតា ដ្បិតគាត់ចាស់ព្រាត្រា ទ្រមទ្រមងងឹតងងល់ ដើរទៅណាមកណាមិនរួច, កាលខ្ញុំនៅជាមួយតែងហុចទឹកចំណីពលថ្ងៃ បើឥតពីខ្ញុំហើយ មុខជាស្លាប់នៅកន្លែងនុះមិនខាន អាស្រ័យហេតុនោះ បានជាខ្ញុំមិនបរិភោគចំណី សុំប្រចុយស្លាប់ បើរស់នៅមិនគាប់ទេ ស្លាប់ទៅប្រសើរជាង ៗ ដោយអំណាចអានិសង្សដែលជនបាលកៈទំនុកបំរុងមាតា ក៏បណ្តាលទឹកព្រះទ័យស្តេចឲ្យអាណិតអាសូរ ទើបទ្រង់ប្រើឲ្យហ្មនាំយកទៅទុកត្រង់កន្លែងដដែលវិញ ៗ

ចំណែកមេដំរីដែលនៅនាញកក្តុំនោះ ដល់នូវសេចក្តីទុក្ខវេទនាពន់ប្រមាណ ព្រោះព្រាត់ប្រាសចាកកូនទីងអត់ទឹកចំណី ក៏ខ្ញូញយំរៀបរាប់ថា: “ឱ! កូនមាសមេតែមួយ អ្នកទៅឯណាបាត់សូន្យឈឹងម្ល៉េះ ប្រហែលជាត្រូវព្រានព្រៃបាញ់ស្លាប់ ឬគេទាក់យកទៅធ្វើជាពាហនៈ ម្ល៉េះសមបើស្ទើរអំពៅព្រៃ ដំមកុងគង់លាស់ទ្របទ្រុល យ៉ាងណា

ទៅអេះ" ។ កាលនោះសេនាបតីដល់ ហើយថ្លែងប្រាប់រឿងនោះសព្វគ្រប់ មេដំរីមានចិត្តត្រេកអរ ហើយឲ្យសាធុការពរដល់ស្តេចពារាណសីថា: "ព្រះរាជាអង្គឯណា ទ្រង់បានលែងកូនខ្ញុំដែលជាអ្នកគោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ សូមឲ្យព្រះរាជានោះបានចំរើនដោយសិរីសម្បត្តិក្នុងដែនកាសី សូមឲ្យមានព្រះជន្មាយុយឺនយូរអស់រយវស្សា" ។

ក្នុងពុទ្ធសាសនា, ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់លើកសរសើរបុគ្គលជាមាតាបិតានិងបុត្រធីតាដែលបំរើមាតាបិតានោះ ដោយអនេកប្បការ ដូចន័យមានមកក្នុងសព្រហ្មកសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយតិកនិបាត ថា "មាតាបិតាឈ្មោះថា "ព្រហ្ម" ផង ថា "បុព្វទេព" ផង ថា "បុព្វាចារ្យ" ផង ថា "អាហុនេយ្យបុគ្គល" ផង របស់កូនប្រុសស្រី ។ បានជាមាតាបិតា ឈ្មោះថា "ព្រហ្ម" ព្រោះលោកមានព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ផ្សាយស្រោចស្រពលើកូនប្រុសស្រី ។ បានជាឈ្មោះថា "បុព្វទេព" សេចក្តីថា វិសុទ្ធិទេព គឺព្រះខីណាស្រព លោកមិនអើពើប្រកាន់កំហុសដែលជនពាលធ្វើបាបលើលោក មានតែប្រាថ្នានូវសេចក្តីចំរើនដល់បុគ្គលពាលនោះតែម្យ៉ាង បើគេគោរពបូជាដល់លោក រមែងបានផលានិសង្សច្រើន យ៉ាងណា; មាតាបិតាក៏មិនប្រកាន់កំហុសរបស់កូនប្រុសស្រី លោកប្រាថ្នាតែសេចក្តីចំរើនដល់កូន បើកូនណាគោរពប្រតិបត្តិបូជា រមែងបានផលានិសង្សច្រើន យ៉ាងនោះដែរ ។ (មានត)

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី
# របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ-ឃុន នាមឆាយាឥន្ទត្ថេរ កើតឆ្នាំកុរ អាយុ ២៧ វស្សា៦ ជាចៅអធិការវត្តគគ្គា ឃុំតាំងក្រសាំង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-ផង់ នាមឆាយាផលត្ថេរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៨ ជាចៅអធិការវត្តឯកលិផល ឃុំចោងម៉ោង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មៀច-រស់ នាមឆាយាសុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៤៥ វស្សា ២៣ ជាចៅអធិការវត្តសំពេង ឃុំដីដុច ស្រុកចុងក្នុំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-រុង នាមឆាយា ឥន្ទមុនីត្ថេរ កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ន-រត់ នាមឆាយា វិនយត្ថេរ កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៩ ជាចៅអធិការវត្តព្រៃបត្ត ឃុំចាម ស្រុកកំពង់ត្របែក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-ព្រំ នាមងារសុវណ្ណកេសរ កើតឆ្នាំច អាយុ ៥២ វស្សា ២៧ ជាចៅអធិការវត្តបេង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហុក-ដេត នាមងារធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៧៣ វស្សា ៥២ ជាចៅអធិការវត្តទឹកជុំ ឃុំពោងម៉ោងស្រុកទឹកផុះ ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៦៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជុម-ឈុម នាមងារគីរីសុធម្ម កើតឆ្នាំកុរ អាយុ ៣៩ វស្សា ១៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-សាម នាមងារធម្មសិរីបញ្ញា កើតឆ្នាំជូត អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេងវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួន-ផាន នាមងារ... កើតឆ្នាំជូត អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្តជ្រោយអន្ស្រោប ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហុង-សេង នាមងារជោតញ្ញាណោ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ៣ ជាចៅអធិការវត្តអញ្ចាញ ឃុំឫស្សីត្រោក ស្រុកមង្គលបូរី ខេត្តបាត់ដំបង ។

(មានត)

ECOLE FRANÇAISE (BIBLIOTHÈQUE) D'EXTRÊME-ORIENT

# កែពាក្យខុសក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៥០

## សៀវភៅលេខ ១

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| រាជ ៧ ថ្ងៃ | រាជ ៣ ខែ | ៦៤ | ៣ |

## សៀវភៅលេខ ៧

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ក្រិត្យានុភាព | កិត្យានុភាព | ៤៨៤ | ១៥ |
| ព. ស. ១០១១ | គ. ស. ១០១១ | ៤៨៩ | ១៥ |
| ព្រឹត្តិការ | ព្រឹត្តិការណ៍ | ៤៩០ | ១៦ |
| នៅមហានគរ | នៅមហានរក | ៤៩០ | ១៧ |
| ដូចនិយដ្ឋាន | បូជនិយដ្ឋាន | ៤៩១ | ១ |
| Olifarchie | Oligarchie | ៤៩២ | ៧ |
| ស្រុះស្រុល | ស្រុះស្រួល | ៥០២ | ១៧ |

## សៀវភៅលេខ ៨

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| គ្រង់ខែគ្រ ១ | គ្រង់ពិភព | ៦០១ | ១១ |